រៀបរៀងដោយ លឹម ផល្គុន

បរិញ្ញាបត្រផ្នែកគណិតវិទ្យានិង ពាណិជ្ជកម្ម

# អាំងតេក្រាលកំណត់

## សម្រាប់ត្រៀមប្រឡងអាហារូបករណ៍នានា

$$\frac{\pi}{3\sqrt{3}} \le \int_0^1 \frac{dx}{x^3+x^2+1} \le \frac{\pi}{4}$$

រក្សាសិទ្ធិ

# អាំងតេក្រាលកំណត់

## សម្រាប់ត្រៀមប្រឡងអាហារូបករណ៍

$$\int_0^{\sqrt{3}} e^{-x^2}.dx \le \frac{\pi}{3}$$

រក្សាសិទ្ធិ ដោយ លឹម ផល្គុន

Tel: 017 768 246

www.mathtoday.wordpress.com

## គណៈកម្មការនិពន្ធ និង រៀបរៀង

លឹម ផល្គុន និង អ៊ឹង សំណាង

## គណៈកម្មការត្រួតពិនិត្យបច្ចេកទេស

លោក យ៉ង់ ឆារី
លោក លឹម ឆុន
លោក សែន ពិសិដ្ឋ

## គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក លឹម មិត្តសិរ

## ការិយកុំព្យូទ័រ

លោក អ៊ឹង សំណាង

# អារម្ភកថា

សួស្តីមិត្តអ្នកសិក្សាជាទីស្រឡាញ់រាប់អាន !

សៀវភៅ **អាំងតេក្រាលកំណត់** ដែលលោកអ្នកកំពុងតែកាន់អាននេះ ខ្ញុំបាទបានរៀបចំឡើងសម្រាប់ទុកជាឯកសារសម្រាប់អ្នកសិក្សាដែលមានបំណងត្រៀមប្រឡងយកអាហារូបករណ៍ទៅសិក្សានៅបរទេស និង សម្រាប់ត្រៀមប្រឡងអាហារូបករណ៍ចូលគ្រឹះស្ថានឧត្តមសិក្សានានាក្នុងប្រទេស។ យើងខ្ញុំបានជ្រើសរើសលំហាត់ពិសេសៗមកធ្វើដំណោះស្រាយ យ៉ាងពិស្តារព្រមទាំងមានលំហាត់អនុវត្តន៍សម្រាប់អ្នកសិក្សាហ្វឹកហាត់ដោះស្រាយដោយខ្លួនឯង។

យើងខ្ញុំសង្ឃឹមថា សៀវភៅមួយក្បាលនេះ នឹងអាចចូលរួមផ្តល់នូវគំនិត និង វិធីសាស្ត្រថ្មីៗក្នុងការដោះស្រាយលំហាត់គណិតវិទ្យាកំរិតអាហារូបករណ៍ ចំពោះលោកអ្នកសិក្សាជាពុំខានឡើយ ។

ជាទីបញ្ចប់ខ្ញុំបាទសូមជូនពរចំពោះលោកអ្នក សូមមានសុខភាពល្អ មានប្រាជ្ញាឈ្លាសវៃ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ។

បាត់ដំបងថ្ងៃទី០៣មិថុនា ឆ្នាំ២០១២

អ្នកនិពន្ធ និង ស្រាវជ្រាវ

**លឹម ផល្គុន**

Tel :017 768 246

Email: lim_phalkun@ymail.com

**Website: www.mathtoday.wordpress.com**

## លំហាត់ទី១

គេឲ្យអាំងតេក្រាល $I_n = \int_0^1 x^n e^{-2x}.dx \ ; n \in IN$

ក/សិក្សាអថេរភាពនៃ $(I_n)$ រួចរកទំនាក់ទំនងរវាង $I_n$ និង $I_{n+1}$ ។

ខ/ស្រាយថា $\forall n \geq 2 : \ 0 \leq I_n \leq \frac{1}{(n-1)e^2}$ ។ ទាញរក $\lim_{n\to+\infty} I_n$ ។

(ប្រឡងអាហារូបករណ៍នៅប្រទេសចិនថ្នាក់ឧត្តមឆ្នាំ២០០២)

## ដំណោះស្រាយ

ក/សិក្សាអថេរភាពនៃ $(I_n)$ រួចរកទំនាក់ទំនងរវាង $I_n$ និង $I_{n+1}$ ៖

ចំពោះគ្រប់ $x \in [0,1]$ និង $n \in IN$ គេមាន $x^{n+1} \leq x^n$

គុណអង្គទាំងពីរនឹង $e^{-2x}$ គេបាន $x^{n+1}e^{-2x} \leq x^n e^{-2x}$

នាំឲ្យ $\int_0^1 x^{n+1}e^{-2x}.dx \leq \int_0^1 x^n e^{-2x}.dx$ ឬ $I_{n+1} \leq I_n$ ។

ដូចនេះ $I_n$ ជាស្វ៊ីតចុះ ។

ម្យ៉ាងទៀត $I_n = \int_0^1 x^n e^{-2x}.dx \;\; ; n \in IN$ នាំឲ្យ $I_{n+1} = \int_0^1 x^{n+1} e^{-2x}.dx$

តាង $\begin{cases} u = x^{n+1} \\ dv = e^{-2x}.dx \end{cases} \Rightarrow \begin{cases} du = (n+1)x^n.dx \\ v = -\frac{1}{2}e^{-2x} \end{cases}$

គេបាន $I_{n+1} = \left[ -\frac{1}{2} e^{-2x} x^{n+1} \right]_0^1 + \frac{n+1}{2} \int_0^1 x^n e^{-2x}.dx$

ដូច្នេះ $I_{n+1} = -\frac{1}{2e^2} + \frac{n+1}{2} I_n$ ជាទំនាក់ទំនងដែលត្រូវរក ។

ខ/ស្រាយថា $\forall n \ge 2 : \; 0 \le I_n \le \frac{1}{(n-1)e^2}$ រួចទាញរក $\lim\limits_{n \to +\infty} I_n$

គេមាន $(I_n)$ ជាស្វ៊ីតចុះនោះគេបាន $I_{n+1} \le I_n$ តែ $I_{n+1} = -\frac{1}{2e^2} + \frac{n+1}{2} I_n$

គេបាន $-\frac{1}{2e^2} + \frac{n+1}{2} I_n \le I_n$ នាំឲ្យ $I_n \le \frac{1}{(n-1)e^2} (1)$

ហើយ $\forall x \in [0,1] : x^n e^{-2x} \ge 0$ នាំឲ្យ $I_n = \int_0^1 x^n e^{-2x}.dx \ge 0 \;\; (2)$ ។

តាម(1)និង(2) $\forall n \ge 2 : \; 0 \le I_n \le \frac{1}{(n-1)e^2}$ និង $\lim\limits_{n \to +\infty} I_n = 0$ ។

## លំហាត់ទី២ (ប្រឡងនៅប្រទេសហ្វីលីពីន ឆ្នាំ ១៩៩៤)

1/រកបីចំនួនថេរ $A,B,C$ ដែលគ្រប់ $x\neq -1$ គេបាន ៖

$$\frac{x}{x^3+1}=\frac{A}{x+1}+\frac{B(2x-1)}{x^2-x+1}+\frac{c}{x^2-x+1}$$

2/គណនា $I=\int\frac{x\,dx}{x^3+1}$

3/គ្រប់ $n>0$ តាង $J_n=\int_0^n\frac{x}{x^3+1}.dx$ ។

ស្រាយបញ្ជាក់ថា $\lim\limits_{n\to+\infty}J_n=\frac{2\pi}{3\sqrt{3}}$ ។

## ដំណោះស្រាយ

1/រកបីចំនួនថេរ $A,B,C$ ៖

$$\frac{x}{x^3+1}=\frac{A}{x+1}+\frac{B(2x-1)}{x^2-x+1}+\frac{c}{x^2-x+1}$$

$$x=A(x^2-x+1)+B(2x-1)(x+1)+C(x+1)$$

$$x=(A+2B)x^2+(-A+B+C)x+(A-B+C)$$

គេទាញ $\begin{cases}A+2B=0\\-A+B+C=1\\A-B+C=0\end{cases}$ នាំឲ្យ $A=-\frac{1}{3}\,,B=\frac{1}{6}\,,C=\frac{1}{2}$ ។

2/គណនា $I=\int\frac{x\,dx}{x^3+1}$

ចំពោះ $A=-\frac{1}{3}$ , $B=\frac{1}{6}$ , $C=\frac{1}{2}$

គេមានសមភាព $\frac{x}{x^3+1}=-\frac{1}{3}.\frac{1}{x+1}+\frac{1}{6}.\frac{2x-1}{x^2-x+1}+\frac{1}{2}.\frac{1}{x^2-x+1}$ គេ

គេបាន $I=-\frac{1}{3}\int\frac{dx}{x+1}+\frac{1}{6}\int\frac{2x-1}{x^2-x+1}dx+\frac{1}{2}\int\frac{dx}{x^2-x+1}$

$$=-\frac{1}{3}\ln|x+1|+\frac{1}{6}\ln|x^2-x+1|+\frac{1}{2}\int\frac{dx}{(x-\frac{1}{2})^2+\frac{3}{4}}$$

តាង $u=x-\frac{1}{2}$ នោះ $du=dx$

គេបាន $I=\frac{1}{6}\ln\frac{(x^2-x+1)}{(x+1)^2}+\frac{1}{2}\int\frac{du}{u^2+(\frac{\sqrt{3}}{2})^2}$

$$=\frac{1}{6}\ln\frac{x^2-x+1}{(x+1)^2}+\frac{1}{2}.\frac{2}{\sqrt{3}}\arctan(\frac{2u}{\sqrt{3}})+C$$ ដោយ $u=x-\frac{1}{2}$

ដូចនេះ $I=\frac{1}{6}\ln\frac{x^2-x+1}{(x+1)^2}+\frac{1}{\sqrt{3}}\arctan(\frac{2x-1}{\sqrt{3}})+C$ ។

3/ស្រាយបញ្ជាក់ថា $\lim_{n\to+\infty} J_n = \frac{2\pi}{3\sqrt{3}}$

គ្រប់ $n > 0$ គេមាន $J_n = \int_0^n \frac{x}{x^3+1}.dx$

តាមសម្រាយខាងលើគេមាន

$$I = \int \frac{xdx}{x^3+1} = \frac{1}{6}\ln\frac{x^2-x+1}{(x+1)^2} + \frac{1}{\sqrt{3}}\arctan(\frac{2x-1}{\sqrt{3}}) + C$$

គេបាន $J_n = \left[\frac{1}{6}\ln\frac{x^2-x+1}{(x+1)^2} + \frac{1}{\sqrt{3}}\arctan(\frac{2x-1}{\sqrt{3}})\right]_0^n$

$$= \frac{1}{6}\ln\frac{n^2-n+1}{(n+1)^2} + \frac{1}{\sqrt{3}}\arctan(\frac{2n-1}{\sqrt{3}}) - \frac{1}{\sqrt{3}}\arctan(-\frac{1}{\sqrt{3}})$$

$$= \frac{1}{6}\ln\frac{n^2-n+1}{(n+1)^2} + \frac{1}{\sqrt{3}}\arctan(\frac{2n-1}{\sqrt{3}}) + \frac{\pi}{6\sqrt{3}}$$

គេបាន $\lim_{n\to+\infty} J_n = \lim_{n\to+\infty}[\frac{1}{6}\ln\frac{n^2-n+1}{(n+1)^2} + \frac{1}{\sqrt{3}}\arctan(\frac{2n-1}{\sqrt{3}}) + \frac{\pi}{6\sqrt{3}}]$

ដោយ $\lim_{n\to+\infty} \ln\frac{n^2-n+1}{(n+1)^2} = 0$ , $\lim_{n\to+\infty} \arctan(\frac{2n-1}{\sqrt{3}}) = \frac{\pi}{2}$

ដូចនេះ $\lim_{n\to+\infty} J_n = \frac{\pi}{2\sqrt{3}} + \frac{\pi}{6\sqrt{3}} = \frac{2\pi}{3\sqrt{3}}$ ។

**លំហាត់ទី៣** (ប្រឡងនៅប្រទេសម៉ាលេស៊ីឆ្នាំ ១៩៩៨ )

គេឲ្យអាំងតេក្រាល $I_n = \int_0^1 x^n\sqrt{1-x}.dx$ ដែល $n$ ជាចំនួនគត់មិនអវិជ្ជមាន

ក/រកទំនាក់ទំនងរវាង $I_n$ និង $I_{n-1}$ ។

ខ/គណនា $\lim_{n\to\infty}\frac{I_{n-1}}{I_n}$ ។

គ/គណនា $I_0$ រួចទាញរក $I_n$ ។

## ដំណោះស្រាយ

ក/រកទំនាក់ទំនងរវាង $I_n$ និង $I_{n-1}$ ៖

មាន $I_n = \int_0^1 x^n\sqrt{1-x}.dx$

តាង $\begin{cases} u = x^n \\ dv = \sqrt{1-x}.dx \end{cases} \Rightarrow \begin{cases} du = nx^{n-1}.dx \\ v = \int \sqrt{1-x}dx = -\frac{2}{3}(1-x)\sqrt{1-x} \end{cases}$

$$I_n = \left[-\frac{2x^n}{3}(1-x)\sqrt{1-x}\right]_0^1 + \frac{2n}{3}\int_0^1 x^{n-1}(1-x)\sqrt{1-x}dx$$

$$I_n = \frac{2n}{3}\int_0^1 x^{n-1}\sqrt{1-x}.dx - \frac{2n}{3}\int_0^1 x^n\sqrt{1-x}.dx$$

$$I_n = \frac{2n}{3}I_{n-1} - \frac{2n}{3}I_n$$

$$(1+\frac{2n}{3})I_n = \frac{2n}{3}I_{n-1}$$

ដូចនេះ $I_n = \frac{2n}{2n+3}\, I_{n-1}$ ជាទំនាក់ទំនងដែលត្រូវរក ។

ខ/គណនា $\lim\limits_{n\to\infty}\frac{I_{n-1}}{I_n}$

តាមសម្រាយខាងលើគេមាន $I_n = \frac{2n}{2n+3}\, I_{n-1}$

នោះ $\frac{I_{n-1}}{I_n} = \frac{2n+3}{2n} = 1 + \frac{3}{2n}$

គេបាន $\lim\limits_{n\to\infty}\frac{I_{n-1}}{I_n} = \lim\limits_{n\to\infty}(1+\frac{3}{2n}) = 1$ ។ ដូចនេះ $\lim\limits_{n\to\infty}\frac{I_{n-1}}{I_n} = 1$ ។

គ/គណនា $I_0$ រួចទាញរក $I_n$ ៖

បើ $n = 0$ នោះ $I_0 = \int_0^1 \sqrt{1-x}.dx$

តាង $\sqrt{1-x} = t$ នាំឲ្យ $x = 1 - t^2$ នោះ $dx = -t.dt$

បើ $x=0$ នោះ $t=1$ និង $x=1$ នោះ $t=0$

គេបាន $I_0=\int_1^0 t.(-2tdt)=\int_0^1 2t^2.dx=\left[\frac{2}{3}t^3\right]_0^1=\frac{2}{3}$

ដូចនេះ $I_0=\frac{2}{3}$ ។ ម្យ៉ាងទៀត $I_n=\frac{2n}{2n+3}I_{n-1}$ នោះ $\frac{I_n}{I_{n-1}}=\frac{2n}{2n+3}$

បើ $n=1$ នោះ $\frac{I_1}{I_0}=\frac{2}{5}$

បើ $n=2$ នោះ $\frac{I_2}{I_1}=\frac{4}{7}$

បើ $n=3$ នោះ $\frac{I_3}{I_2}=\frac{6}{9}$

-----------------------------------

បើ $n=n$ នោះ $\frac{I_{n-1}}{I_n}=\frac{2n}{2n+3}$

គុណអង្គនិងអង្គគេបាន $\frac{I_n}{I_0}=\frac{2\times 4\times 6\times ....\times 2n}{5\times 7\times 9\times ...\times(2n+3)}$ ដោយ $I_0=\frac{2}{3}$

ដូចនេះ $I_n=\frac{2\times 4\times 6\times ....\times 2n}{5\times 7\times 9\times ...\times(2n+3)}\times\frac{2}{3}$ ។

**លំហាត់ទី៤** (ប្រឡងអាហារូបករណ៍ប្រទេសចិនឆ្នាំ១៩៩៦)

គេឲ្យអាំងតេក្រាល $I_n = \int_0^{\frac{\pi}{2}} \cos^n x.dx \text{ , } n \in IN$

1/រកទំនាក់ទំនងរវាង $I_n$ និង $I_{n-2}$ ។

2/ទាញរក $I_{2p}$ និង $I_{2p+1}$ ដែល $p \in IN$ ។

## ដំណោះស្រាយ

1/រកទំនាក់ទំនងរវាង $I_n$ និង $I_{n-2}$ ៖

មាន $I_n = \int_0^{\frac{\pi}{2}} \cos^n x.dx = \int_0^{\frac{\pi}{2}} \cos^{n-1} x.\cos x.dx \text{ , } n \in IN$

តាង $\begin{cases} u = \cos^{n-1} x \\ dv = \cos x.dx \end{cases} \Rightarrow \begin{cases} du = -(n-1)\sin x \cos^{n-2} x.dx \\ v = \sin x \end{cases}$

$$I_n = \left[\cos^{n-1} x \sin x\right]_0^{\frac{\pi}{2}} + (n-1)\int_0^{\frac{\pi}{2}} \sin^2 x \cos^{n-2} x.dx$$

$$I_n = (n-1)\int_0^{\frac{\pi}{2}} (1-\cos^2 x)\cos^{n-2} x.dx$$

$$I_n = (n-1)\int_0^{\frac{\pi}{2}} \cos^{n-2} x.dx - (n-1)\int_0^{\frac{\pi}{2}} \cos^n x.dx$$

$$I_n = (n-1)I_{n-2} - (n-1)I_n \Rightarrow I_n = \frac{n-1}{n}.I_{n-2}$$

ដូចនេះ $I_n = \frac{n-1}{n} I_{n-2}$ ,

2/ទាញរក $I_{2p}$ និង $I_{2p+1}$ ដែល $p \in IN$ ៖

គេមាន $I_n = \frac{n-1}{n} I_{n-2}$ នោះ $\frac{I_n}{I_{n-2}} = \frac{n-1}{n}$

-បើ $n = 2k$ នោះ $\frac{I_{2k}}{I_{2k-2}} = \frac{2k}{2k-1}$

គេបាន $\prod_{k=1}^{p} \frac{I_{2k}}{I_{2k-2}} = \prod_{k=1}^{n} \frac{2k-1}{2k}$

$$\frac{I_2}{I_0}.\frac{I_4}{I_2}.\frac{I_6}{I_4}...\frac{I_{2p}}{I_{2p-2}} = \frac{1\times3\times5\times....\times(2p-1)}{2\times4\times6\times.......\times2p}$$

$$I_{2p} = \frac{1\times3\times5\times....\times(2p-1)}{2\times4\times6\times......\times2p}\times I_0$$

តែ $I_0 = \int_0^{\frac{\pi}{2}} dx = \frac{\pi}{2}$ ដូចនេះ $I_{2p} = \frac{1\times3\times5\times....\times(2p-1)}{2\times4\times6\times......\times2p}\times\frac{\pi}{2}$ ។

-បើ $n = 2k+1$ នោះ $\frac{I_{2k+1}}{I_{2k-1}} = \frac{2k}{2k+1}$

គេបាន $\prod_{k=1}^{p} \frac{I_{2k+1}}{I_{2k-1}} = \prod_{k=1}^{n} \frac{2k}{2k+1}$

$$\frac{I_3}{I_1}.\frac{I_5}{I_3}.\frac{I_7}{I_5}...\frac{I_{2p+1}}{I_{2p-1}} = \frac{2\times 4\times 6\times ....\times 2p}{3\times 5\times 7\times .......\times 2p+1}$$

$$I_{2p+1} = \frac{2\times 4\times 6\times ....\times (2p)}{3\times 5\times 7\times ......\times 2p+1}\times I_1$$

តែ $I_1 = \int_0^{\frac{\pi}{2}} \cos x dx = [\sin x]_0^{\frac{\pi}{2}} = 1$

ដូចនេះ $I_{2p+1} = \frac{2\times 4\times 6\times ....\times (2p)}{3\times 5\times 7\times ......\times 2p+1}$ ។

**លំហាត់ទី៥**(ប្រឡងនៅប្រទេសអូស្រ្តាលីផ្នែកអេឡិចត្រូនិច )

គេឲ្យអាំងតេក្រាល $\mathbf{I_n = \int_0^1 x^n\sqrt{1-x}.dx}$ ដែល $\mathbf{n = 0,1,2,...}$

ក/រក $\mathbf{I_0}$ រួចបង្កើតទំនាក់ទំនងរវាង $\mathbf{I_n}$ និង $\mathbf{I_{n-1}}$ ។ គណនា $\mathbf{I_n}$ ។

ខ/ស្រាយបញ្ជាក់ថា $\mathbf{I_n < \frac{1}{\sqrt{(n+1)^3}}}$ ។

**ដំណោះស្រាយ**

ក/រក $\mathbf{I_0}$ រួចបង្កើតទំនាក់ទំនងរវាង $\mathbf{I_n}$ និង $\mathbf{I_{n-1}}$ ៖

បើ $\mathbf{n = 0}$ នោះ $\mathbf{I_0 = \int_0^1 \sqrt{1-x}.dx}$

តាង $\mathbf{\sqrt{1-x} = t}$ នាំឲ្យ $\mathbf{x = 1-t^2}$ នោះ $\mathbf{dx = -t.dt}$

បើ $\mathbf{x = 0}$ នោះ $\mathbf{t = 1}$ និង $\mathbf{x = 1}$ នោះ $\mathbf{t = 0}$

គេបាន $\mathbf{I_0 = \int_1^0 t.(-2tdt) = \int_0^1 2t^2.dx = \left[\frac{2}{3}t^3\right]_0^1 = \frac{2}{3}}$

ដូចនេះ $\mathbf{I_0 = \frac{2}{3}}$ ។

ម្យ៉ាងទៀតគេមាន $I_n = \int_0^1 x^n \sqrt{1-x}.dx$

តាង $\begin{cases} u = x^n \\ dv = \sqrt{1-x}.dx \end{cases} \Rightarrow \begin{cases} du = nx^{n-1}.dx \\ v = \int \sqrt{1-x}dx = -\frac{2}{3}(1-x)\sqrt{1-x} \end{cases}$

$$I_n = \left[ -\frac{2x^n}{3}(1-x)\sqrt{1-x} \right]_0^1 + \frac{2n}{3}\int_0^1 x^{n-1}(1-x)\sqrt{1-x}dx$$

$$I_n = \frac{2n}{3}\int_0^1 x^{n-1}\sqrt{1-x}.dx - \frac{2n}{3}\int_0^1 x^n\sqrt{1-x}.dx$$

$$I_n = \frac{2n}{3}I_{n-1} - \frac{2n}{3}I_n$$

$$(1+\frac{2n}{3})I_n = \frac{2n}{3}I_{n-1}$$

ដូចនេះ $I_n = \frac{2n}{2n+3}I_{n-1}$ ជាទំនាក់ទំនងដែលត្រូវរក ។

គណនា $I_n$ ៖

គេមាន $I_n = \frac{2n}{2n+3}I_{n-1}$ នោះ $\frac{I_n}{I_{n-1}} = \frac{2n}{2n+3}$

គេបាន $\prod_{k=1}^{n}\frac{I_k}{I_{k-1}} = \prod_{k=1}^{n}\frac{2k}{2k+3}$

ឬ $\frac{I_n}{I_0}=\frac{2\times4\times6\times....\times2n}{5\times7\times9\times...\times(2n+3)}$ ដោយ $I_0=\frac{2}{3}$

ដូចនេះ $I_n=\frac{2\times4\times6\times....\times2n}{5\times7\times9\times...\times(2n+3)}\times\frac{2}{3}$ ។

ខ/ស្រាយបញ្ជាក់ថា $I_n<\frac{1}{\sqrt{(n+1)^3}}$

គេមាន $I_n=\frac{2\times4\times6\times....\times2n}{5\times7\times9\times...\times(2n+3)}\times\frac{2}{3}$

$$=\frac{2\times4\times6\times....\times(2n+2)}{3\times5\times7\times....\times(2n+3)}\times\frac{1}{n+1}=\frac{1}{n+1}\prod_{k=1}^{n+1}\frac{2k}{2k+1}$$

តាមវិសមភាពមធ្យមនព្វន្ត និង មធ្យមធរណីមាត្រចំពោះគ្រប់ $k\in IN$

គេមាន $(2k)+(2k+2)\geq2\sqrt{(2k)(2k+2)}$ ឬ $2k+1\geq\sqrt{2k(2k+2)}$

គេទាញ $\frac{2k}{2k+1}\leq\frac{2k}{\sqrt{2k(2k+2)}}=\sqrt{\frac{k}{k+1}}$

គេបាន $I_n\leq\frac{1}{n+1}\prod_{k=1}^{n+1}\sqrt{\frac{k}{k+1}}=\frac{1}{(n+1)\sqrt{n+2}}<\frac{1}{(n+1)\sqrt{n+1}}$

ដូចនេះ $I_n<\frac{1}{\sqrt{(n+1)^3}}$ ។

## លំហាត់ទី៦

គេឲ្យអនុគមន៍ f និង g កំណត់ដោយ ៖

$$f(x)=\begin{cases}\dfrac{\sin\pi x}{1-x} & \text{បើ } x\neq 1\\ \pi & \text{បើ } x=1\end{cases}$$ និង $$g(x)=\begin{cases}\dfrac{x^n\sin\pi x}{1-x} & \text{បើ } 0\leq x<1\\ \pi & \text{បើ } x=1\end{cases}$$

1/ស្រាបញ្ជាក់ថាf និង g ជាអនុគមន៍ជាប់លើចន្លោះ $[0,1]$ ។

2/គណនា $S_n=I_0+I_1+I_2+...+I_{n-1}$ ដែល $I_n=\int_0^1 x^n\sin\pi x.dx$ ។

3/ស្រាយថា$S_n=\int_0^1 f(x).dx-\int_0^1 g(x).dx$ រួចទាញថា $\lim_{n\to+\infty}S_n=\int_0^\pi \frac{\sin x}{x}.dx$

## ដំណោះស្រាយ

1/ស្រាបញ្ជាក់ថាf និង g ជាអនុគមន៍ជាប់លើចន្លោះ $[0,1]$

គេមាន $\lim_{x\to1}\frac{\sin\pi x}{1-x}=\lim_{t\to0}\frac{\sin\pi(1-t)}{t}=\lim_{t\to0}\frac{\sin\pi}{\pi t}\times\pi=\pi=f(1)$

ដូចគ្នាដែរ $\lim_{x\to1}g(x)=\lim_{x\to1}\frac{x^n\sin\pi x}{1-x}=\lim_{x\to1}[x^n f(x)]=\pi=g(1)$

ដូចនេះ f ជាអនុគមន៍ជាប់លើ$[0,1]$ ។

2/គណនា $S_n = I_0 + I_1 + I_2 + ... + I_{n-1}$ ដែល $I_n = \int_0^1 x^n \sin\pi x.dx$

គេបាន $S_n = \int_0^1 (1 + x + x^2 + ... + x^{n-1})\sin\pi x.dx = \int_0^1 \frac{1 - x^n}{1 - x}\sin\pi x.dx$

$$= \int_0^1 \frac{\sin\pi x}{1 - x}.dx - \int_0^1 \frac{x^n \sin\pi x}{1 - x}.dx$$ ។

3/ស្រាយថា $S_n = \int_0^1 f(x).dx - \int_0^1 g(x).dx$ និង $\lim\limits_{n\to+\infty} S_n = \int_0^\pi \frac{\sin x}{x}.dx$

គេមាន $= \int_0^1 \frac{\sin\pi x}{1 - x}.dx - \int_0^1 \frac{x^n \sin\pi x}{1 - x}.dx$ ។

ដោយ $f(x) = \frac{\sin\pi x}{1 - x}$ និង $g(x) = \frac{x^n \sin\pi x}{1 - x}$ កំណត់ជាប់លើ $[0,1]$ ។

ដូចនេះ $S_n = \int_0^1 f(x).dx - \int_0^1 g(x).dx$ ។

ដោយ $f$ និង $g$ ជាអនុគមន៍កំណត់ និង ជាប់លើ $[0,1]$

នោះគ្រប់ $x \in [0,1]$ មាន $M > 0$ ដែល $|f(x)| < M$

ហើយនិង $|g(x)| = x^n |f(x)| < M.x^n$ ។

នាំឲ្យ $|\int_0^1 g(x).dx| \le \int_0^1 |g(x)|\,dx < M.\int_0^1 x^n.dx = \frac{M}{n+1}$

ដោយ $\lim_{n\to+\infty}\frac{M}{n+1} = 0$ នោះ $\lim_{n\to\infty}\int_0^1 g(x).dx = 0$

គេទាញ $\lim_{n\to+\infty} S_n = \int_0^1 \frac{\sin \pi x}{1-x}.dx$ (1)

តាង $1-x = t$ ឬ $x = 1-t \Rightarrow dx = -dt$

បើ $x=0$ នោះ $t=1$ និង $x=1$ នោះ $t=0$

គេបាន $\int_0^1 \frac{\sin \pi x}{1-x}.dx = \int_1^0 \frac{\sin \pi(1-t)}{t}(-dt) = \int_0^1 \frac{\sin \pi t}{t}.dt$ (2)

តាង $x = \pi t \Rightarrow dx = \pi.dt$

បើ $t=0$ នោះ $x=0$ និង $t=1$ នោះ $t=\pi$

គេបាន $\int_0^1 \frac{\sin \pi t}{t}.dt = \int_0^\pi \frac{\sin x}{x}.dx$ (3)

តាម (1) , (2) និង (3) គេបាន $\lim_{n\to+\infty} S_n = \int_0^\pi \frac{\sin x}{x}.dx$ ពិត ។

## លំហាត់ទី៧

លើអង្កត់ $[0,\frac{\pi}{2}]$ ដែលត្រូវនឹងចំនួនគត់ធម្មជាតិ $n\in IN$ គេកំណត់អនុគមន៍

$$f_n(x)=\begin{cases}\frac{\sin(nx)}{\sin x} & \text{បើ } x>0\\ n & \text{បើ } x=0\end{cases}$$

1/ស្រាយថា $f_n(x)$ មានអាំងតេក្រាលលើ អង្កត់ $[0,\frac{\pi}{2}]$ ។

2/តាង $I_n=\int_0^{\frac{\pi}{2}} f_n(x).dx$ ។ រកទំនាក់ទំនងរវាង $I_{2n+1}$ និង $I_{2n-1}$ ។

## ដំណោះស្រាយ

1/ស្រាយថា $f_n(x)$ មានអាំងតេក្រាលលើ អង្កត់ $[0,\frac{\pi}{2}]$ ៖

គេមាន $\lim\limits_{x\to 0} f_n(x)=\lim\limits_{x\to 0}\frac{\sin(nx)}{\sin x}=n\lim\limits_{x\to 0}\frac{\sin(nx)}{(nx)}.\frac{x}{\sin x}=n=f(0)$

នាំឲ្យ $f_n$ ជាអនុគមន៍ជាប់ត្រង់ $x=0$ នោះ $f_n$ ជាប់លើ $[0,\frac{\pi}{2}]$ ។

ដូចនេះ $f_n(x)$ មានអាំងតេក្រាលលើ $[0,\frac{\pi}{2}]$ ។

2/ រកទំនាក់ទំនងរវាង $I_{2n+1}$ និង $I_{2n-1}$

គេមាន $I_n = \int_0^{\frac{\pi}{2}} \frac{\sin(nx)}{\sin x}.dx$ នោះ $I_{2n-1} = \int_0^{\frac{\pi}{2}} \frac{\sin(2n-1)x}{\sin x}.dx$

និង $I_{2n+1} = \int_0^{\frac{\pi}{2}} \frac{\sin(2n+1)x}{\sin x}.dx$ ។

គេបាន $I_{2n+1} - I_{2n-1} = \int_0^{\frac{\pi}{2}} \frac{\sin(2n+1)x - \sin(2n-1)x}{\sin x}.dx$

$$= \int_0^{\frac{\pi}{2}} \frac{2\sin x \cos(2nx)}{\sin x}.dx$$

$$= 2\int_0^{\frac{\pi}{2}} \cos(2nx).dx = \frac{1}{n}\left[\sin(2nx)\right]_0^{\frac{\pi}{2}} = 0$$

ដូចនេះ $I_{2n+1} = I_{2n-1}$ ។

# លំហាត់ទី៨

គេឲ្យ $I_n = \int_0^{\frac{\pi}{2}} \sin^n x.dx$ ដែល n ជាចំនួនគត់មិនអវិជ្ជមាន ។

1/រកទំនាក់ទំនងរវាង $I_n$ និង $I_{n+2}$ ។

2/ស្រាយបញ្ជាក់ថាអនុគមន៍ $f(n) = (n+1)I_n.I_{n+1}$

ផ្ទៀងផ្ទាត់ $f(n+1) = f(n)$ ។

3/គណនា $f(n)$ ។

# ដំណោះស្រាយ

1/រកទំនាក់ទំនងរវាង $I_n$ និង $I_{n+2}$ ៖

គេមាន $I_n = \int_0^{\frac{\pi}{2}} \sin^n x.dx$ នោះ $I_{n+2} = \int_0^{\frac{\pi}{2}} \sin^{n+2} xdx = \int_0^{\frac{\pi}{2}} \sin^{n+1} x.\sin xdx$

តាង $\begin{cases} u = \sin^{n+1} x \\ dv = \sin x.dx \end{cases} \Rightarrow \begin{cases} du = (n+1)\cos x \sin^n x.dx \\ v = -\cos x \end{cases}$

គេបាន $I_{n+2} = \left[-\sin^{n+1} x \cos x\right]_0^{\frac{\pi}{2}} + (n+1)\int_0^{\frac{\pi}{2}} \cos^2 x \sin^n x.dx$

$$I_{n+2} = (n+1)\int_0^{\frac{\pi}{2}} (1-\sin^2 x)\sin^n x.dx$$

$$I_{n+2} = (n+1)\int_0^{\frac{\pi}{2}} \sin^n x.dx - (n+1)\int_0^{\frac{\pi}{2}} \sin^{n+2} x.dx$$

$I_{n+2} = (n+1)I_n - (n+1)I_{n+2}$ នាំឲ្យ $I_{n+2} = \frac{n+1}{n+2} I_n$ ។

2/បញ្ជាក់ថាអនុគមន៍ $f(n) = (n+1)I_n.I_{n+1}$ ផ្ទៀងផ្ទាត់ $f(n+1) = f(n)$

គេមាន $f(n) = (n+1)I_n.I_{n+1}$ នោះ $f(n+1) = (n+2)I_{n+1}.I_{n+2}$

តែ $I_{n+2} = \frac{n+1}{n+2} I_n$ នោះ $f(n+1) = (n+2).I_{n+1}\frac{n+1}{n+2}I_n = (n+1)I_nI_{n+1}$

ដូចនេះ $f(n+1) = f(n)$ ។

3/គណនា $f(n)$ ៖

ដោយ $f(n+1) = f(n)$ នោះ $f(n)$ ជាអនុគមន៍ថេរ ។

គេបាន $f(n) = f(0) = I_0.I_1$ ដោយ $I_0 = \int_0^{\frac{\pi}{2}} dx = \frac{\pi}{2}$ និង $I_1 = \int_0^{\frac{\pi}{2}} \sin x.dx = 1$

ដូចនេះ $f(n) = \frac{\pi}{2}$ ។

# លំហាត់ទី៩

គេឲ្យអាំងតេក្រាល $I_n = \int_0^1 x(1+x)^n.dx$ ដែល $n = 0,1,2,...$ ។

តាង $S_n = I_0 + I_1 + I_2 + .... + I_n$ ។

ក/ចូរស្រាយថា $S_n = -1 + \int_0^1 (1+x)^{n+1}.dx$ ។

ខ/គណនា $S_n$ រួចទាញរក $I_n$ ។

គ/ដោយប្រើលទ្ធផលខាងលើចូរទាញថា៖

$$\frac{1}{2}C_n^0 + \frac{1}{3}C_n^1 + \frac{1}{4}C_n^2 + .... + \frac{1}{n+2}C_n^n = \frac{n.2^{n+1}+1}{(n+1)(n+2)}$$ ។

# ដំណោះស្រាយ

ក/ស្រាយថា $S_n = -1 + \int_0^1 (1+x)^{n+1}.dx$

គេមាន $I_n = \int_0^1 x(1+x)^n.dx = \int_0^1 \left[(x+1)-1\right](1+x)^n.dx$

$$I_n = \int_0^1 (x+1)^{n+1}.dx - \int_0^1 (x+1)^n.dx$$

គេបាន $S_n = \sum_{k=0}^{n}(I_k) = \sum_{k=0}^{n}\left[\int_0^1 (1+x)^{k+1}.dx - \int_0^1 (1+x)^k.dx\right]$

$$= \int_0^1 (1+x)^{n+1}.dx - \int_0^1 dx$$ ដោយ $\int_0^1 dx = 1$

ដូចនេះ $S_n = -1 + \int_0^1 (1+x)^{n+1}.dx$ ។

ខ/គណនា $S_n$ រួចទាញរក $I_n$ ៖

គេមាន $S_n = -1 + \int_0^1 (1+x)^{n+1}.dx$

$$= -1 + \left[\frac{1}{n+2}(1+x)^{n+2}\right]_0^1 = -1 + \frac{2^{n+2}-1}{n+2}$$

ដូចនេះ $S_n = -1 + \frac{2^{n+2}-1}{n+2}$ ។

ម្យ៉ាងទៀត $S_n = I_0 + I_1 + ... + I_n = S_{n-1} + I_n$ នោះ $I_n = S_n - S_{n-1}$

$$I_n = (-1 + \frac{2^{n+2}-1}{n+2}) - (-1 + \frac{2^{n+1}-1}{n+1}) = \frac{n.2^{n+1}+1}{(n+1)(n+2)}$$

ដូចនេះ $I_n = \frac{n.2^{n+1}+1}{(n+1)(n+2)}$ ។

គ/ដោយប្រើលទ្ធផលខាងលើចូរទាញថា៖

$$\frac{1}{2}C_n^0 + \frac{1}{3}C_n^1 + \frac{1}{4}C_n^2 + .... + \frac{1}{n+2}C_n^n = \frac{n.2^{n+1}+1}{(n+1)(n+2)}$$

តាមទ្វេធាញូតុន $(1+x)^n = C_n^0 + C_n^1 x + C_n^2 x^2 + .... + C_n^n x^n$

គុណអង្គទាំងពីរនឹង $x$ គេបាន ៖

$$x(1+x)^n = C_n^0 x + C_n^1 x^2 + C_n^2 x^3 + .... + C_n^n x^{n+1}$$

ធ្វើអាំងតេក្រាលកំណត់ពី **0** ទៅ **1** លើសមភាពនេះគេបាន ៖

$$\int_0^1 x(1+x)^n.dx = \int_0^1 (C_n^0 x + C_n^1 x^2 + C_n^2 x^3 + .... + C_n^n x^{n+1}).dx$$

$$I_n = \left[ \frac{1}{2}C_n^0 x^2 + \frac{1}{3}C_n^1 x^3 + \frac{1}{4}C_n^2 x^4 + .... + \frac{1}{n+2}C_n^n x^{n+2} \right]_0^1$$

$$I_n = \frac{1}{2}C_n^0 + \frac{1}{3}C_n^1 + \frac{1}{4}C_n^2 + .... + \frac{1}{n+2}C_n^n$$

ដោយ $I_n = \frac{n.2^{n+1}+1}{(n+1)(n+2)}$ (តាមសម្រាយខាងលើ )

ដូចនេះ $\frac{1}{2}C_n^0 + \frac{1}{3}C_n^1 + \frac{1}{4}C_n^2 + .... + \frac{1}{n+2}C_n^n = \frac{n.2^{n+1}+1}{(n+1)(n+2)}$ ។

## លំហាត់ទី១០ (ប្រឡងសាលាច្បាប់-សេដ្ឋកិច្ច ២៦/១០/១៩៩៧)

គេឲ្យ $I_n = \int_0^{\frac{\pi}{2}} \cos^n x.dx \ , \ n \in IN$

ក/រកទំនាក់ទំនង $I_n$ និង $I_{n-2}$ ដែលមាន $n$ ។

ខ/គេសន្មត $I_{2p} = \frac{1\times 3\times ....\times(2p-1)}{2\times 4\times 6\times .....\times(2p)}\times\frac{\pi}{2}$

និង $I_{2p+1} = \frac{2\times 4\times 6\times .....\times 2p}{1\times 3\times 5\times .....\times(2p+1)}$ ។ បង្ហាញថា $\frac{I_{2p+2}}{I_{2p}} \le \frac{I_{2p+1}}{I_{2p}} \le 1$ រួច

ទាញរក $\lim\limits_{p\to+\infty} \frac{(2\times 4\times 6\times ....\times 2p)^2}{[1\times 3\times 5\times ....\times(2p-1)]^2}\times\frac{1}{2p+1}$ ។

## ដំណោះស្រាយ

ក/រកទំនាក់ទំនង $I_n$ និង $I_{n-2}$ ដែលមាន $n$ ៖

មាន $I_n = \int_0^{\frac{\pi}{2}} \cos^n x.dx = \int_0^{\frac{\pi}{2}} \cos^{n-1} x.\cos x.dx \ , \ n \in IN$

តាង $\begin{cases} u = \cos^{n-1} x \\ dv = \cos x.dx \end{cases} \Rightarrow \begin{cases} du = -(n-1)\sin x\cos^{n-2} x.dx \\ v = \sin x \end{cases}$

$$I_n = \left[\cos^{n-1} x \sin x\right]_0^{\frac{\pi}{2}} + (n-1)\int_0^{\frac{\pi}{2}} \sin^2 x \cos^{n-2} x.dx$$

$$I_n = (n-1)\int_0^{\frac{\pi}{2}} (1-\cos^2 x)\cos^{n-2} x.dx$$

$$I_n = (n-1)\int_0^{\frac{\pi}{2}} \cos^{n-2} x.dx - (n-1)\int_0^{\frac{\pi}{2}} \cos^n x.dx$$

$$I_n = (n-1)I_{n-2} - (n-1)I_n \Rightarrow I_n = \frac{n-1}{n}.I_{n-2}$$

ដូចនេះ $I_n = \frac{n-1}{n} I_{n-2}$ ។

ខ/បង្ហាញថា $\frac{I_{2p+2}}{I_{2p}} \le \frac{I_{2p+1}}{I_{2p}} \le 1$

គ្រប់ $x \in [0, \frac{\pi}{2}]$ និង $p \in IN$ គេមាន $\cos^{2p+2} x \le \cos^{2p+1} x \le \cos^{2p} x$

គេបាន $\int_0^{\frac{\pi}{2}} \cos^{2p+2} x.dx \le \int_0^{\frac{\pi}{2}} \cos^{2p+1} x.dx \le \int_0^{\frac{\pi}{2}} \cos^{2p} x.dx$

ឬ $I_{2p+2} \le I_{2p+1} \le I_{2p}$ នាំឲ្យ $\frac{I_{2p+2}}{I_{2p}} \le \frac{I_{2p+1}}{I_{2p}} \le 1$ ។

ទាញរក $\lim\limits_{p\to+\infty}\frac{(2\times4\times6\times....\times2p)^2}{[1\times3\times5\times....\times(2p-1)]^2}\times\frac{1}{2p+1}$ ៖

គេមាន $I_n=\frac{n-1}{n}I_{n-2}$ នោះ $I_{2p+2}=\frac{2p+1}{2p}I_{2p}$ ឬ $\frac{I_{2p+2}}{I_{2p}}=\frac{2p+1}{2p}$

ដោយ $\frac{I_{2p+2}}{I_{2p}}\le\frac{I_{2p+1}}{I_{2p}}\le1$ នោះ $\frac{2p+1}{2p}\le\frac{I_{2p+1}}{I_{2p}}\le1$

ដោយ $\lim\limits_{p\to+\infty}\frac{2p+1}{2p}=1$ គេទាញ $\lim\limits_{n\to+\infty}\frac{I_{2p+1}}{I_{2p}}=1$ ។

មាន $I_{2p}=\frac{1\times3\times....\times(2p-1)}{2\times4\times6\times.....\times(2p)}\times\frac{\pi}{2}$ និង $I_{2p+1}=\frac{2\times4\times6\times.....\times2p}{1\times3\times5\times.....\times(2p+1)}$

គេបាន $\frac{I_{2p+1}}{I_{2p}}=\frac{(2\times4\times6\times....\times2p)^2}{[1\times3\times5\times....\times(2p-1)]^2}\times\frac{1}{2p+1}\times\frac{2}{\pi}$

គេទាញ $\frac{(2\times4\times6\times....\times2p)^2}{[1\times3\times5\times....\times(2p-1)]^2}\times\frac{1}{2p+1}=\frac{\pi}{2}.\frac{I_{2p+1}}{I_{2p}}$

ដោយ $\lim\limits_{n\to+\infty}\frac{I_{2p+1}}{I_{2p}}=1$ (សម្រាយខាងលើ)

ដូចនេះ $\lim\limits_{p\to+\infty}\frac{(2\times4\times6\times....\times2p)^2}{[1\times3\times5\times....\times(2p-1)]^2}\times\frac{1}{2p+1}=\frac{\pi}{2}$ ។

## លំហាត់ទី១១

គេឲ្យអនុគមន៍ $f(x)=\frac{1}{x(x+1)}$

1/គ្រប់ $a$ វិជ្ជមាន គណនា $F(a)=\int_1^a f(x).dx$

2/គ្រប់ $n\in IN$ គេតាង $S_n=F(1)+F(2)+....+F(n)$ ។

គណនា $S_n$ រួចរកលីមីតរបស់ស្វ៊ីត $(S_n)$ កាលណា $n\to+\infty$ ។

## ដំណោះស្រាយ

1/គ្រប់ $a$ វិជ្ជមាន គណនា $F(a)=\int_1^a f(x).dx$

គេមាន $f(x)=\frac{1}{x(x+1)}=\frac{1}{x}-\frac{1}{x+1}$

គេបាន $F(a)=\int_1^a(\frac{1}{x}-\frac{1}{x+1}).dx$

$$=\left[\ln|x|-\ln|x+1|\right]_1^a=\left[\ln|\frac{x}{x+1}|\right]_1^a$$

$$=\ln(\frac{a}{a+1})-\ln\frac{1}{2}=\ln\frac{2a}{a+1}\ ,\ a>0$$

2/គណនា $S_n$ រួចរកលីមីតរបស់ស្វ៊ីត $(S_n)$ កាលណា $n \to +\infty$

គេមាន $S_n = F(1) + F(2) + .... + F(n) = \sum_{k=1}^{n} F(k)$ ដោយ $F(a) = \ln \frac{2a}{a+1}$

គេបាន $S_n = \sum_{k=1}^{n} \ln(\frac{2k}{k+1}) = \ln[\prod_{k=1}^{n} \frac{2k}{k+1}] = \ln \frac{2^n}{n+1}$

ដូចនេះ $S_n = \ln \frac{2^n}{n+1}$ ។

ហើយ $\lim_{n\to+\infty} S_n = \lim_{n\to+\infty} \ln \frac{2^n}{n+1} = +\infty$ ( ព្រោះ $\lim_{n\to\infty} \frac{2^n}{n+1} = +\infty$ )។

# លំហាត់ទី១២

គណនាអាំងតេក្រាល $I=\int_0^1 \sqrt{\frac{x}{x^3+1}}.dx$

# ដំណោះស្រាយ

គណនាអាំងតេក្រាល $I=\int_0^1 \sqrt{\frac{x}{x^3+1}}.dx$

គេអាចសរសេរ $I=\int_0^1 \frac{x^{\frac{1}{2}}.dx}{\sqrt{x^3+1}}$ តាង $t=x^{\frac{3}{2}}$ នោះ $dt=\frac{3}{2}x^{\frac{1}{2}}.dx$

បើ $x=0$ នោះ $t=0$ និង $x=1$ នោះ $t=1$ ។

គេបាន $I=\frac{2}{3}\int_0^1 \frac{dt}{\sqrt{t^2+1}}$ តាង $t=\tan\varphi$ នោះ $dt=(1+\tan^2\varphi)d\varphi$

បើ $t=0$ នោះ $\varphi=0$ និង $t=1$ នោះ $\varphi=\frac{\pi}{4}$ ។

គេបាន $I=\frac{2}{3}\int_0^{\frac{\pi}{4}} \frac{(1+\tan^2\varphi)d\varphi}{\sqrt{1+\tan^2\varphi}}=\frac{2}{3}\int_0^{\frac{\pi}{4}} \frac{d\varphi}{\cos\varphi}=\frac{2}{3}\int_0^{\frac{\pi}{4}} \frac{\cos\varphi.d\varphi}{1-\sin^2\varphi}$

តាង $u=\sin\varphi$ នោះ $du=\cos\varphi.d\varphi$

បើ $\varphi = 0$ នោះ $u = 0$ និង $\varphi = \frac{\pi}{4}$ នោះ $u = \frac{1}{\sqrt{2}}$

គេបាន $I = \frac{2}{3}\int_0^{\frac{1}{\sqrt{2}}} \frac{du}{1-u^2} = \frac{1}{3}\int_0^{\frac{1}{\sqrt{2}}} (\frac{1}{1-u} + \frac{1}{1+u})du$

$$I = \frac{1}{3}\left[-\ln|1-u| + \ln|1+u|\right]_0^{\frac{1}{\sqrt{2}}} = \frac{1}{3}\ln(\frac{\sqrt{2}+1}{\sqrt{2}-1})$$

ដោយ $\frac{\sqrt{2}+1}{\sqrt{2}-1} = (\sqrt{2}+1)^2$ នោះ $I = \frac{1}{3}\ln(\sqrt{2}+1)^2$

ដូចនេះ $I = \frac{2}{3}\ln(\sqrt{2}+1)$ ។

## លំហាត់ទី១៣

គេឲ្យអាំងតេក្រាល $I_n = \int_0^{\pi} x\sin^n x.dx$ ដែល $n = 0,1,2,...$ ។

ក ចូរស្រាយថា/$I_n = \pi\int_0^{\frac{\pi}{2}} \sin^n x.dx$ ។

ខ ចំពោះគ្រប់/$n \ge 2$ ស្រាយថា $I_n = \frac{n-1}{n} I_{n-2}$ ។

## ដំណោះស្រាយ

ក ស្រាយថា/$I_n = \pi\int_0^{\frac{\pi}{2}} \sin^n x.dx$

គេមាន $I_n = \int_0^{\pi} x\sin^n x.dx$ ដែល $n = 0,1,2,...$

តាង $x = \pi - t$ នោះ $dx = -dt$

បើ $x = 0$ នោះ $t = \pi$ និង $x = \pi$ នោះ $t = 0$

គេបាន $I_n = \int_{\pi}^{0} (\pi - t)\sin^n(\pi - t)(-dt)$

$$I_n=\int_0^{\pi}(\pi-t)\sin^n t.dt=\pi\int_0^{\pi}\sin^n tdt-\int_0^{\pi}t\sin^n t.dt$$

$I_n=\pi\int_0^{\pi}\sin^n x.dx-I_n$ នាំឲ្យ $I_n=\frac{\pi}{2}\int_0^{\pi}\sin^n x.dx$ (1)

គេមាន $\int_0^{\pi}\sin^n x.dx=\int_0^{\frac{\pi}{2}}\sin^n x.dx+\int_{\frac{\pi}{2}}^{\pi}\sin^n x.dx$ (2)

តាង $x=\pi-t$ នោះ $dx=-dt$

បើ $x=\frac{\pi}{2}$ នោះ $t=\frac{\pi}{2}$ និង $x=\pi$ នោះ $t=0$

គេបាន $\int_{\frac{\pi}{2}}^{\pi}\sin^n x.dx=\int_{\frac{\pi}{2}}^{0}\sin^n(\pi-t)(-dt)=\int_0^{\frac{\pi}{2}}\sin^n t.dt$ (3)

តាម គេបាន (3) និង (2) $\int_{\frac{\pi}{2}}^{\pi}\sin^n x.dx=2\int_0^{\frac{\pi}{2}}\sin^n x.dx$ (4)

យក គេបាន (1) ជំនួសក្នុង(4) $I_n=\pi\int_0^{\frac{\pi}{2}}\sin^n x.dx$ ពិត ។

ខ ចំពោះគ្រប់/$n \geq 2$ ស្រាយថា $I_n = \frac{n-1}{n} I_{n-2}$

គេមាន $I_n = \pi \int_0^{\frac{\pi}{2}} \sin^n x.dx = \pi \int_0^{\frac{\pi}{2}} \sin^{n-1} x . \sin x dx$

តាង $\begin{cases} u = \sin^{n-1} x \\ dv = \sin x.dx \end{cases}$ នាំឲ្យ $\begin{cases} du = (n-1)\cos x \sin^{n-2} x.dx \\ v = \int \sin x dx = -\cos x \end{cases}$

$$I_n = \pi \left[ -\sin^{n-1} x \cos x \right]_0^{\frac{\pi}{2}} + (n-1)\pi \int_0^{\frac{\pi}{2}} \cos^2 x \sin^{n-2} x.dx$$

$$I_n = (n-1)\pi \int_0^{\frac{\pi}{2}} (1-\sin^2 x)\sin^{n-2} x.dx$$

$$I_n = (n-1)\pi \int_0^{\frac{\pi}{2}} \sin^{n-2} x.dx - (n-1)\pi \int_0^{\frac{\pi}{2}} \sin^n x.dx$$

$$I_n = (n-1)I_{n-2} - (n-1)I_n$$

គេទាញ $nI_n = (n-1)I_{n-2}$ ឬ $I_n = \frac{n-1}{n} I_{n-2}$ ។

ដូចនេះ $I_n = \frac{n-1}{n} I_{n-2}$ ។

## លំហាត់ទី១៤

គេឲ្យអាំងតេក្រាល ៖

$$I_n=\int_{\frac{\pi}{6}}^{\frac{\pi}{3}}\frac{\sin^n x}{\sin^n x+\cos^n x}.dx \quad \text{និង} \quad J_n=\int_{\frac{\pi}{6}}^{\frac{\pi}{3}}\frac{\cos^n x}{\sin^n x+\cos^n x}.dx$$

ក ចូរស្រាយថា/$I_n=J_n$ ។

ខ គណនា/$I_n$ និង $J_n$ ។

## ដំណោះស្រាយ

ក/ស្រាយថា $I_n=J_n$

មាន $I_n=\int_{\frac{\pi}{6}}^{\frac{\pi}{3}}\frac{\sin^n x}{\sin^n x+\cos^n x}.dx$ និង $J_n=\int_{\frac{\pi}{6}}^{\frac{\pi}{3}}\frac{\cos^n x}{\sin^n x+\cos^n x}.dx$

ចំពោះ $I_n=\int_{\frac{\pi}{6}}^{\frac{\pi}{3}}\frac{\sin^n x}{\sin^n x+\cos^n x}.dx$ តាង $x=\frac{\pi}{2}-t$ នោះ $dx=-dt$

បើ $x=\frac{\pi}{6}$ នោះ $t=\frac{\pi}{3}$ និង $x=\frac{\pi}{3}$ នោះ $t=\frac{\pi}{6}$

គេបាន $I_n = \int_{\frac{\pi}{3}}^{\frac{\pi}{6}} \frac{\sin^n(\frac{\pi}{2} - t)}{\sin^n(\frac{\pi}{2} - t) + \cos^n(\frac{\pi}{2} - t)}.(-dt)$

$$I_n = \int_{\frac{\pi}{6}}^{\frac{\pi}{3}} \frac{\cos^n t}{\cos^n t + \sin^n t}.dt = J_n$$

ដូចនេះ $I_n = J_n$ ។

ខ គណនា/$I_n$ និង $J_n$ ៖

គេបាន$I_n + J_n = \int_{\frac{\pi}{6}}^{\frac{\pi}{3}} \frac{\sin^n x}{\sin^n x + \cos^n x}.dx + \int_{\frac{\pi}{6}}^{\frac{\pi}{3}} \frac{\cos^n x}{\sin^n x + \cos^n x}.dx$

$$I_n + J_n = \int_{\frac{\pi}{6}}^{\frac{\pi}{3}} dx = \frac{\pi}{3} - \frac{\pi}{6} = \frac{\pi}{6}$$ តែ $I_n = J_n$

នោះ $2I_n = 2J_n = \frac{\pi}{6}$ នាំឲ្យ $I_n = J_n = \frac{\pi}{12}$ ។

ដូចនេះ$I_n = \frac{\pi}{12}$ និង $J_n = \frac{\pi}{12}$ ។

## លំហាត់ទី១៥

គេឲ្យអាំងតេក្រាល $I_{\alpha} = \int_{0}^{\sqrt{\alpha}} x^3 e^{-x^2}.dx$ ដែល $\alpha > 0$ ។

គណនា $I_{\alpha}$ ជាអនុគមន៍នៃ $\alpha$ រួចគណនា $\lim_{\alpha \to +\infty} I_{\alpha}$ ។

## ដំណោះស្រាយ

គណនា $I_{\alpha}$ ជាអនុគមន៍នៃ $\alpha$ រួចគណនា $\lim_{\alpha \to +\infty} I_{\alpha}$

គេមាន $I_{\alpha} = \int_{0}^{\sqrt{\alpha}} x^3 e^{-x^2}.dx$ ដែល $\alpha > 0$

តាង $\begin{cases} u = x^2 \\ dv = xe^{-x^2}dx \end{cases}$ នាំឲ្យ $\begin{cases} du = 2x.dx \\ v = -\frac{1}{2}e^{-x^2} \end{cases}$

គេបាន $I_{\alpha} = \left[ -\frac{x^2}{2}e^{-x^2} \right]_0^{\sqrt{\alpha}} + \int_{0}^{\sqrt{\alpha}} xe^{-x^2}.dx$

$$= -\frac{\alpha}{2}e^{-\alpha} - \left[ \frac{1}{2}e^{-x^2} \right]_0^{\sqrt{\alpha}} = -\frac{1}{2}\alpha e^{-\alpha} - (\frac{1}{2}e^{-\alpha} - \frac{1}{2})$$

ដូចនេះ $I_{\alpha} = \frac{1}{2} - \frac{\alpha + 1}{2}e^{-\alpha}$ និង $\lim_{\alpha \to +\infty} I_{\alpha} = \frac{1}{2}$ ។

# លំហាត់ទី១៦

គេមានអាំងតេក្រាល $I_n = \int_0^1 \frac{x^n}{x^2 + x + 1}.dx$ ដែល $n = 0,1,2,...$

ក ស្រាយថា/$(I_n)$ ជាស្វ៊ីតចុះ រួចគណនា $I_n + I_{n+1} + I_{n+2}$ ។

ខ គណនាលីមីត/ $\lim_{n\to+\infty}(nI_n)$ ។

# ដំណោះស្រាយ

ក ស្រាយថា/$(I_n)$ ជាស្វ៊ីតចុះ

គេមាន $I_n = \int_0^1 \frac{x^n}{x^2 + x + 1}.dx$ និង $I_{n+1} = \int_0^1 \frac{x^{n+1}}{x^2 + x + 1}.dx$

ចំពោះគ្រប់ $x \in [0,1]$ និង $n \in IN$ គេមាន $x^n \geq x^{n+1}$

នាំឲ្យ $\frac{x^n}{x^2 + x + 1} \geq \frac{x^{n+1}}{x^2 + x + 1}$ នោះ $I_n \geq I_{n+1}$ ។

ដូចនេះ $(I_n)$ ជាស្វ៊ីតចុះ ។

គណនា $I_n + I_{n+1} + I_{n+2}$ ៖

គេបាន $I_n + I_{n+1} + I_{n+2} = \int_0^1 \frac{x^n + x^{n+1} + x^{n+2}}{x^2 + x + 1}.dx$

$$= \int_0^1 \frac{x^n(1 + x + x^2)}{x^2 + x + 1}.dx$$

$$= \int_0^1 x^n.dx = \left[\frac{x^{n+1}}{n+1}\right]_0^1 = \frac{1}{n+1}$$

ដូចនេះ $I_n + I_{n+1} + I_{n+2} = \frac{1}{n+1}$ ។

ខ គណនាលីមីត/ $\lim_{n\to+\infty}(nI_n)$ ៖

គេមាន $I_n + I_{n+1} + I_{n+2} = \frac{1}{n+1}$ (1)

គេបាន $I_{n-2} + I_{n-1} + I_n = \frac{1}{n-1}$ (2) គ្រប់ $n \geq 2$ ។

ដោយ $(I_n)$ ជាស្វ៊ីតចុះនោះចំពោះគ្រប់ $n \geq 2$ គេមាន

$I_{n+2} \leq I_{n+1} \leq I_n \leq I_{n-1} \leq I_{n-2}$

នាំឲ្យ $I_n + I_{n+1} + I_{n+2} \leq 3I_n \leq I_{n-2} + I_{n-1} + I_n$ (3)

តាម (1), (2) និង គេទាញបាន ៖ (3)

$$\frac{1}{n+1} \le 3I_n \le \frac{1}{n-1}$$

នាំឲ្យ $\frac{n}{3(n+1)} \le n I_n \le \frac{n}{3(n-1)}$

ដោយ $\lim_{n\to\infty} \frac{n}{3(n+1)} = \lim_{n\to\infty} \frac{n}{3(n-1)} = \frac{1}{3}$

ដូចនេះ $\lim_{n\to\infty} (nI_n) = \frac{1}{3}$ ។

## លំហាត់ទី១៧

គេឲ្យអាំងតេក្រាល $I_n = \int_0^n \frac{dx}{8x^2+6x+1}$ ដែល $n > 0$

គណនា $I_n$ ជាអនុគមន៍នៃ $n$ រួចទាញរកលីមីត $\lim\limits_{n\to+\infty} I_n$ ។

## ដំណោះស្រាយ

គណនា $I_n$ ជាអនុគមន៍នៃ $n$ រួចទាញរកលីមីត $\lim\limits_{n\to+\infty} I_n$

គេមាន $I_n = \int_0^n \frac{dx}{8x^2+6x+1}$ ដែល $n > 0$

តាង $f(x) = \frac{1}{8x^2+6x+1} = \frac{1}{(2x+1)(4x+1)}$

សរសេរ $f(x)$ ជារាងកាណូនិច $f(x) = \frac{a}{2x+1} + \frac{b}{4x+1}$

គេបាន $\frac{a}{2x+1} + \frac{b}{4x+1} = \frac{1}{8x^2+6x+1}$

នាំឲ្យ $a(4x+1) + b(2x+1) = 1$

ឬ $(4a+2b)x + (a+b) = 1$

គេទាញ $\begin{cases} 4a+2b=0 \\ a+b=1 \end{cases}$ នាំឲ្យ $a=-1\ ,\ b=2$

គេបាន $f(x)=-\dfrac{1}{2x+1}+\dfrac{2}{4x+1}$

$$I_n=\int_0^n f(x).dx=\int_0^n\left(\frac{2}{4x+1}-\frac{1}{2x+1}\right).dx$$

$$=\int_0^n\frac{2dx}{4x+1}-\int_0^n\frac{dx}{2x+1}$$

$$=\frac{1}{2}\left[\ln|4x+1|\right]_0^n-\frac{1}{2}\left[\ln|2x+1|\right]_0^n$$

$$=\frac{1}{2}\ln(4n+1)-\frac{1}{2}\ln(2n+1)=\ln\sqrt{\frac{4n+1}{2n+1}}$$

ដូចនេះ $I_n=\ln\sqrt{\dfrac{4n+1}{2n+1}}$ និង $\lim\limits_{n\to\infty} I_n=\lim\limits_{n\to\infty}\ln\sqrt{\dfrac{4n+1}{2n+1}}=\ln\sqrt{2}$ ។

## លំហាត់ទី១៨

គេឲ្យអាំងតេក្រាល $I_n = \int_0^1 \frac{t^{3n}}{1+t^3}.dt$ ដែល $n = 0, 1, 2, ...$ ។

ចូរគណនាលីមីត $\lim_{n\to+\infty} (nI_n)$ ។

## ដំណោះស្រាយ

គណនាលីមីត $\lim_{n\to+\infty} (nI_n)$

គេមាន $I_n = \int_0^1 \frac{t^{3n}}{1+t^3}.dt$ ដែល $n = 0, 1, 2, ...$

គេបាន $I_{n+1} = \int_0^1 \frac{t^{3n+3}}{1+t^3}.dt$

$$I_n + I_{n+1} = \int_0^1 \frac{t^{3n} + t^{3n+3}}{1+t^3}.dt = \int_0^1 t^{3n}.dt = \left[\frac{t^{3n+1}}{3n+1}\right]_0^1 = \frac{1}{3n+1}$$

$I_n + I_{n+1} = \frac{1}{3n+1}$ (1) និង $I_{n-1} + I_n = \frac{1}{3n-2}$ (2)

គ្រប់ $t \in [0, 1]$ គេមាន $t^{3n} \geq t^{3n+3}$ នាំឲ្យ $\frac{t^{3n}}{1+t^3} \geq \frac{t^{3n+3}}{1+t^3}$

គេទាញ $\int_0^1 \frac{t^{3n}}{1+t^3}dt \ge \int_0^1 \frac{t^{3n+3}}{1+t^3}.dt$ ឬ $I_n \ge I_{n+1}$ គ្រប់ $n = 0,1,2,...$

នាំឲ្យ $(I_n)$ ជាស្វ៊ីតចុះ ។ តាមលក្ខណៈនៃស្វ៊ីតចុះគេបាន ៖

$I_{n+1} \le I_n \le I_{n-1}$ នាំឲ្យ $\frac{I_{n+1}+I_n}{2} \le I_n \le \frac{I_n + I_{n-1}}{2}$ **(3)**

យកទំនាក់ទំនងគេបាន ៖(3)ជំនួសក្នុង(2)និង(1)

$\frac{1}{6n+2} \le I_n \le \frac{1}{6n-4}$ នាំឲ្យ $\frac{n}{6n+2} \le nI_n \le \frac{n}{6n-4}$

ដោយ $\lim_{n\to\infty} \frac{n}{6n+2} = \lim_{n\to\infty} \frac{n}{6n-4} = \frac{1}{6}$

ដូចនេះ $\lim_{n\to+\infty} (n I_n) = \frac{1}{6}$ ។

# លំហាត់ទី១៩

គេឲ្យ f ជាអនុគមន៍កំណត់ពីសំណុំ IR ទៅ IR ហើយផ្ទៀងផ្ទាត់

សមីការ $f(x+1)+x^2f(x^3+1)=x^3+\sqrt[3]{x}$ គ្រប់ $x\in IR$ ។

ចូរគណនាអាំងតេក្រាល $I=\int_1^2 f(x).dx$ ។

# ដំណោះស្រាយ

គណនាអាំងតេក្រាល $I=\int_1^2 f(x).dx$

បើគេតាង- $x=t+1$ នោះ $dx=dt$

ចំពោះ $x=1$ នោះ $t=0$ និង $x=2$ នោះ $t=1$ ។

គេបាន $I=\int_1^2 f(x).dx=\int_0^1 f(t+1).dt \quad (1)$

បើគេតាង- $x=t^3+1$ នោះ $dx=3t^2dt$

ចំពោះ $x=1$ នោះ $t=0$ និង $x=2$ នោះ $t=1$ ។

គេបាន $I=\int_1^2 f(x).dx = 3\int_0^1 t^2 f(t+1).dt$

ឬ $\frac{1}{3}I=\int_0^1 t^2 f(t^3+1).dt \quad (2)$

បូកសមីការ គេបាន ៖ (2) និង (1)

$$I+\frac{1}{3}I=\int_0^1 [f(t+1)+t^2f(t^3+1)].dt$$

ដោយ $f(x+1)+x^2f(x^3+1)=x^3+\sqrt[3]{x}$ គ្រប់ $x\in IR$ ។

គេបាន $\frac{4}{3}I=\int_0^1 (t^3+\sqrt[3]{t}).dt=\left[\frac{1}{4}t^4+\frac{3}{4}t^{\frac{4}{3}}\right]_0^1=1$

ដូចនេះ $I=\frac{3}{4}$ ។

# លំហាត់ទី២០

គេឲ្យអាំងតេក្រាល $I_n = \int_{(n-1)\pi}^{n\pi} e^{-x}\sin x.dx$ ដែល $n = 1,2,3,...$ ។

ក ចូរគណនា $I_1$ ។

ខបង្ហាញថា $(I_n)$ ជាស្វ៊ីតធរណីមាត្ររួចទាញរក $I_n$ ជាអនុគមន៍នៃ $n$ ។

គ គណនាផលបូក $S_n = I_1 + I_2 + ... + I_n$ ជាអនុគមន៍នៃ $n$ ។

ឃ ទាញរកលីមីតនៃ $S_n$ កាលណា $n \to +\infty$ ។

# ដំណោះស្រាយ

គេឲ្យអាំងតេក្រាល $I_n = \int_{(n-1)\pi}^{n\pi} e^{-x}\sin x.dx$ ដែល $n = 1,2,3,...$ ។

ក គណនា $I_1$ ៖

បើ $n = 1$ នោះ $I_1 = \int_0^{\pi} e^{-x}\sin x.dx$

តាង $\begin{cases} u = e^{-x} \\ dv = \sin x.dx \end{cases}$ នាំឲ្យ $\begin{cases} du = -e^{-x}.dx \\ v = -\cos x \end{cases}$

គេបាន៖

$$I_1 = \left[-e^{-x}\cos x\right]_0^{\pi} - \int_0^{\pi} e^{-x}\cos x.dx$$

$$I_1 = 1 + e^{-\pi} - \int_0^{\pi} e^{-x}\cos x.dx$$

តាង $\begin{cases} u = e^{-x} \\ dv = \cos x.dx \end{cases}$ នាំឲ្យ $\begin{cases} du = -e^{-x}.dx \\ v = \sin x \end{cases}$

គេបាន ៖

$$I_1 = 1 + e^{-\pi} - \left[e^{-x}\sin x\right]_0^{\pi} - \int_0^{\pi} e^{-x}\sin x.dx$$

$$I_1 = 1 + e^{-\pi} - I_1$$

ដូចនេះ $I_1 = \frac{1+e^{-\pi}}{2} = \frac{1+e^{\pi}}{2e^{\pi}}$ ។

ខបង្ហាញថា/$(I_n)$ជាស្វ៊ីតធរណីមាត្រ ៖

មាន $I_n = \int_{(n-1)\pi}^{n\pi} e^{-x}\sin x.dx$ នោះ $I_{n+1} = \int_{n\pi}^{(n+1)\pi} e^{-x}\sin x.dx$

តាង $x = \pi + t$ នោះ $dx = dt$

ចំពោះ $x = n\pi$ នោះ $t = (n-1)\pi$ និង $x = (n+1)\pi$ នោះ $t = n\pi$

គេបាន $I_{n+1} = \int_{(n-1)\pi}^{n\pi} e^{-\pi-t}\sin(\pi+t).dt = -e^{-\pi}\int_{(n-1)\pi}^{n\pi} e^{-t}\sin t.dt$

$I_{n+1} = -e^{-\pi}\, I_n$ នាំឲ្យ $(I_n)$ជាស្វ៊ីតធរណីមាត្រ ។

ទាញរក$I_n$ជាអនុគមន៍នៃ$n$៖

តាមរូបមន្ត $I_n = I_1 \times q^{n-1} = \dfrac{1+e^{-\pi}}{2}\times(-e^{-\pi})^{n-1}$ ។

គ គណនាផលបូក/$S_n = I_1 + I_2 + ... + I_n$ ជាអនុគមន៍នៃ$n$៖

គេបាន $S_n = I_1 \times \dfrac{1-q^n}{1-q} = \dfrac{1+e^{-\pi}}{2}\times\dfrac{1-(-e^{-\pi})^n}{1+e^{-\pi}} = \dfrac{1-(-e^{-\pi})^n}{2}$

ឃ ទាញរកលីមីតនៃ/$S_n$ កាលណា $n \to +\infty$ ៖

គេបាន $\lim\limits_{n\to\infty} S_n = \lim\limits_{n\to\infty}\dfrac{1+(-e^{-\pi})^n}{2} = \dfrac{1}{2}$ ព្រោះ $\lim\limits_{n\to\infty}(-e^{-\pi})^n = 0$ ។

ដូចនេះ $\lim\limits_{n\to\infty} S_n = \dfrac{1}{2}$ ។

## លំហាត់ទី២១

គេឱ្យអាំងតេក្រាល $I_n = \int_0^a \frac{x^n.dx}{x^3+a^3}, a>0$

ក. ចូរកំនត់តម្លៃរបស់ $n$ ដើម្បីឱ្យ $I_n$ មិនអាស្រ័យនឹង $a$ ។

ខ. គណនា $I_n$ ចំពោះតម្លៃ $n$ ដែលបានរកឃើញខាងលើ ។

## ដំណោះស្រាយ

ក. កំនត់តម្លៃរបស់ $n$ ដើម្បីឱ្យ $I_n$ មិនអាស្រ័យនឹង $a$

យើងមាន $I_n = \int_0^a \frac{x^n.dx}{x^3+a^3}, a>0$

យើងតាង $x = a.t$ នាំឱ្យ $dx = a.dt$

ហើយចំពោះ $x \in [0,a]$ នាំឱ្យ $t \in [0,1]$

គេបាន $I_n = \int_0^1 \frac{(a.t)^n.a.dt}{(at)^3+a^3} = a^{n-2}.\int_0^1 \frac{t^n.dt}{t^3+1}$

តាមទំនាក់ទំនងនេះ ដើម្បីឱ្យ $I_n$ មិនអាស្រ័យនឹង $a$ លុះត្រាតែ

$n-2=0$ ឬ $n=2$ ។

ដូចនេះ ដើម្បីឱ្យ $I_n$ មិនអាស្រ័យនឹង $a$ គេត្រូវឱ្យ $n=2$ ។

ខ. គណនា $I_n$ ចំពោះតម្លៃ $n$ ដែលបានរកឃើញខាងលើ

ចំពោះ $n=2$ គេបាន $I_2=\int_0^1 \frac{x^2dx}{x^3+1}$

តាង $U=x^3+1$ នាំឱ្យ $dU=3x^2.dx$

ហើយចំពោះ $x\in[0,1]$ នាំឱ្យ $U\in[1\ ,\ 2]$

យើងបាន $I_2=\frac{1}{3}\int_1^2\frac{dU}{U}=\frac{1}{3}\left[\ln|U|\right]_1^2=\frac{1}{3}\ln 2$ ។

ដូចនេះ $\boxed{I_2=\frac{1}{3}\ln 2}$ ។

## លំហាត់ទី២២

គេឱ្យស្វីតអាំងតេក្រាល $I_n = \int_0^1 x^n \sqrt{1-x^2}\,.dx$ ដែល $n \in IN$ ។

ក. ចូររកទំនាក់ទំនងរវាង $I_n$ និង $I_{n-2}$

ខ. គណនាផលគុណ $P_n = I_n . I_{n-1}\ , \forall n \ge 1$ ជាអនុគមន៍នៃ $n$ ។

គ. គណនាផលបូក $S_n = \sum_{k=1}^{n} (P_k) = P_1 + P_2 + ......... + P_n$ ជាអនុគមន៍នៃ $n$

រួចទាញរកតម្លៃនៃលីមីត $\lim_{n \to +\infty} S_n$ ។

ឃ. រករូបមន្តគណនា $I_n$ ជាអនុគមន៍នៃ $n$ ។

## ដំណោះស្រាយ

ក. រកទំនាក់ទំនងរវាង $I_n$ និង $I_{n-2}$

យើងមាន $I_n = \int_0^1 x^n \sqrt{1-x^2}\,.dx$ និង $I_{n-2} = \int_0^1 x^{n-2}.\sqrt{1-x^2}\,.dx$

តាង $\begin{cases} U = \sqrt{1-x^2} \\ dV = x^n.dx \end{cases}$ នាំឱ្យ $\begin{cases} dU = -\dfrac{x}{\sqrt{1-x^2}}.dx \\ V = \int x^n.dx = \dfrac{1}{n+1} x^{n+1} \end{cases}$

យើងបាន $I_n = \left[\frac{1}{n+1}x^{n+1}.\sqrt{1-x^2}\right]_0^1 + \frac{1}{n+1}\int_0^1 \frac{x^{n+2}}{\sqrt{1-x^2}}.dx$

$$I_n = \frac{1}{n+1}\int_0^1 \frac{x^n - (x^n - x^{n+2})}{\sqrt{1-x^2}}.dx = \frac{1}{n+1}\int_0^1 \frac{x^n - x^n(1-x^2)}{\sqrt{1-x^2}}.dx$$

$$I_n = \frac{1}{n+1}\int_0^1 \frac{x^n.dx}{\sqrt{1-x^2}} - \frac{1}{n+1}\int_0^1 x^n\sqrt{1-x^2}.dx$$

$$I_n = \frac{1}{n+1}\int_0^1 x^{n-1}.\frac{xdx}{\sqrt{1-x^2}} - \frac{1}{n+1}I_n$$

តាង $\begin{cases} U = x^{n-1} \\ dV = \frac{xdx}{\sqrt{1-x^2}} \end{cases}$ នាំឱ្យ $\begin{cases} dU = (n-1)x^{n-2}.dx \\ V = -\sqrt{1-x^2} \end{cases}$

យើងបាន

$$I_n = \frac{1}{n+1}\left\{\left[-x^{n-1}\sqrt{1-x^2}\right]_0^1 + (n-1)\int_0^1 x^{n-2}\sqrt{1-x^2}.dx\right\} - \frac{1}{n+1}I_n$$

គេទាញ $(n+1)I_n = (n-1)I_{n-2} - I_n$ នាំឱ្យ $I_n = \frac{n-1}{n+2}I_{n-2}$

ដូចនេះ ទំនាក់ទំនងរវាង $I_n$ និង $I_{n-2}$

គឺ $\boxed{I_n = \frac{n-1}{n+2}I_{n-2}, \forall n \geq 2}$ ។

ខ. គណនាផលគុណ $P_n = I_n.I_{n-1}$ , $\forall n \ge 1$ ជាអនុគមន៍នៃ $n$

យើងមាន $P_n = I_n.I_{n-1}$ នាំឱ្យ $P_{n+1} = I_{n+1}.I_n$

ដោយ $I_n = \frac{n-1}{n+2} I_{n-2}$ នាំឱ្យ $I_{n+1} = \frac{n}{n+3}.I_{n-1}$

គេទាញ $P_{n+1} = \frac{n}{n+3} I_{n-1}.I_n = \frac{n}{n+3} P_n$ ( ព្រោះ $P_n = I_n.I_{n-1}$ )

នាំអោយ $\frac{P_{n+1}}{P_n} = \frac{n}{n+3} = \frac{n}{n+1}.\frac{n+1}{n+2}.\frac{n+2}{n+3}$ ។

យើងបាន $\prod_{k=1}^{(n-1)} \left( \frac{P_{k+1}}{P_k} \right) = \prod_{k=1}^{(n-1)} \left( \frac{k}{k+1}.\frac{k+1}{k+2}.\frac{k+2}{k+3} \right)$

$$\prod_{k=1}^{(n-1)} \left( \frac{P_{k+1}}{P_k} \right) = \prod_{k=1}^{(n-1)} \left( \frac{k}{k+1} \right) \times \prod_{k=1}^{(n-1)} \left( \frac{k+1}{k+2} \right) \times \prod_{k=1}^{(n-1)} \left( \frac{k+2}{k+3} \right)$$

$$\frac{P_2}{P_1}.\frac{P_3}{P_2}....\frac{P_n}{P_{n-1}} = \left( \frac{1}{2}.\frac{2}{3}....\frac{n-1}{n} \right) \times \left( \frac{2}{3}.\frac{3}{4}....\frac{n}{n+1} \right) \times \left( \frac{3}{4}.\frac{4}{5}....\frac{n+1}{n+2} \right)$$

$$\frac{P_n}{P_1} = \frac{1}{n}.\frac{2}{n+1}.\frac{3}{n+2}$$

នាំឱ្យគេទាញ $P_n = \frac{6}{n(n+1)(n+2)}.P_1 = \frac{6}{n(n+1)(n+2)}.I_0.I_1$

ដោយ $I_0 = \int_0^1 \sqrt{1-x^2}.dx = \left[ \frac{x}{2}\sqrt{1-x^2} + \frac{1}{2}\arcsin x \right]_0^1 = \frac{\pi}{4}$

និង $I_1 = \int_0^1 x\sqrt{1-x^2}.dx = \left[ -\frac{1}{3}(1-x^2)^{\frac{3}{2}} \right]_0^1 = \frac{1}{3}$

គេបាន $P_n = \frac{6}{n(n+1)(n+2)}.\frac{\pi}{4}.\frac{1}{3} = \frac{\pi}{2}.\frac{1}{n(n+1)(n+2)}$

ដូចនេះ $\boxed{P_n = \frac{\pi}{2}.\frac{1}{n(n+1)(n+2)}}$ ។

គ. គណនាផលបូក $S_n = \sum_{k=1}^{n}(P_k) = P_1 + P_2 + ......... + P_n$

$$P_n = \frac{\pi}{2}.\frac{1}{n(n+1)(n+2)} = \frac{\pi}{4}\left[\frac{1}{n(n+1)} - \frac{1}{(n+1)(n+2)}\right]$$

យើងបាន $S_n = \frac{\pi}{4}\sum_{k=1}^{n}\left[\frac{1}{k(k+1)} - \frac{1}{(k+1)(k+2)}\right]$

$$= \frac{\pi}{4}\left[(\frac{1}{1.2} - \frac{1}{2.3}) + (\frac{1}{2.3} - \frac{1}{3.4}) + ..... + \left(\frac{1}{n(n+1)} - \frac{1}{(n+1)(n+2)}\right)\right]$$

$$= \frac{\pi}{4}\left[\frac{1}{2} - \frac{1}{(n+1)(n+2)}\right] = \frac{\pi}{8}.\frac{n(n+3)}{(n+1)(n+2)}$$

ដូចនេះ $\boxed{S_n = \frac{\pi}{8}.\frac{n(n+3)}{(n+1)(n+2)}}$ និង $\boxed{\lim_{n\to+\infty} S_n = \frac{\pi}{8}}$ ។

ឃ. រករូបមន្តគណនា $I_n$ ជាអនុគមន៍នៃ $n$

តាមសម្រាយខាងលើយើងមាន $I_n = \frac{n-1}{n+2} I_{n-2}, \forall n \geq 2$

-ករណី $n = 2p+1$ ( ចំនួនសេស )

យើងបាន $I_{2p+1} = \frac{2p}{2p+3} . I_{2p-1}$

ឬ $\frac{I_{2p+1}}{I_{2p-1}} = \frac{2p}{2p+3}$

គេទាញ $\frac{I_3}{I_1} \cdot \frac{I_5}{I_3} \cdot \frac{I_7}{I_5} \cdots\cdots \frac{I_{2p+1}}{I_{2p-1}} = \frac{2}{5} \cdot \frac{4}{7} \cdot \frac{6}{9} \cdots\cdots \frac{2p}{2p+3}$

$$\frac{I_{2p+1}}{I_1} = \frac{2}{5} \cdot \frac{4}{7} \cdot \frac{6}{9} \cdots\cdots \frac{2p}{2p+3}$$

នាំឱ្យ $I_{2p+1} = \frac{2.4.6....2p}{5.7.9....(2p+3)} . I_1$ ដោយ $I_1 = \frac{1}{3}$

ដូចនេះ $\boxed{I_{2p+1} = \frac{2.4.6....2p}{5.7.9....(2p+3)} \cdot \frac{1}{3}}$ ។

-ករណី $\mathbf{n = 2p}$ ( ចំនួនគូ )

យើងបាន $I_{2p} = \frac{2p-1}{2p+2}.I_{2p-2}$ ឬ $\frac{I_{2p}}{I_{2p-2}} = \frac{2p-1}{2p+2}$

គេទាញ $\frac{I_2}{I_0}.\frac{I_4}{I_2}.\frac{I_6}{I_4}.....\frac{I_{2p}}{I_{2p-2}} = \frac{1}{4}.\frac{3}{6}.\frac{5}{8}.....\frac{2p-1}{2p+2}$

$$\frac{I_{2p}}{I_0} = \frac{1}{4}.\frac{3}{6}.\frac{5}{8}.....\frac{2p-1}{2p+2}$$

នាំឱ្យ $I_{2p+1} = \frac{1.3.5....(2p-1)}{4.6.8....(2p+2)}.I_0$ ដោយ $I_0 = \frac{\pi}{4}$

ដូចនេះ $\boxed{I_{2p+1} = \frac{1.3.5....(2p-1)}{4.6.8....(2p+2)}.\frac{\pi}{4}}$ ។

## លំហាត់ទី២៣

ចូរបង្ហាញថា $\int_a^b f(x).dx = \int_a^b f(a+b-x).dx$

អនុវត្តន៍ ៖ ចូរគណនាអាំងតេក្រាល $I = \int_0^{\frac{\pi}{3}} \ln(1+\sqrt{3}\tan x).dx$

## ដំណោះស្រាយ

បង្ហាញថា $\int_a^b f(x).dx = \int_a^b f(a+b-x).dx$

តាង $t = a+b-x \Rightarrow dt = -dx$

បើ $x = a \Rightarrow t = b$ និង $x = b \Rightarrow t = a$

យើងបាន

$$\int_a^b f(x).dx = \int_b^a f(a+b-t)(-dt) = -\int_b^a f(a+b-t).dt = \int_a^b f(a+b-t).dt$$

ដូចនេះ $\int_a^b f(x).dx = \int_a^b f(a+b-x).dx$ ។

គណនាអាំងតេក្រាល $I=\int_0^{\frac{\pi}{3}}\ln(1+\sqrt{3}\tan x).dx$

តាមរូបមន្តខាងលើយើងអាចសរសេរ៖

$$I=\int_0^{\frac{\pi}{3}}\ln\left[1+\sqrt{3}\tan(\frac{\pi}{3}-x)\right].dx=\int_0^{\frac{\pi}{3}}\ln\left(1+\sqrt{3}.\frac{\sqrt{3}-\tan x}{1+\sqrt{3}\tan x}\right).dx$$

$$I=\int_0^{\frac{\pi}{3}}\ln\left(\frac{4}{1+\sqrt{3}\tan x}\right).dx=\int_0^{\frac{\pi}{3}}\left[\ln 4-\ln(1+\sqrt{3}\tan x)\right].dx$$

$$I=\ln 4\int_0^{\frac{\pi}{3}}dx-\int_0^{\frac{\pi}{3}}\ln(1+\sqrt{3}\tan x).dx=\frac{2\pi}{3}\ln 2-I$$

$2I=\frac{2\pi}{3}\ln 2$ នាំឱ្យ $I=\frac{\pi}{3}\ln 2$

ដូចនេះ $\boxed{I=\int_0^{\frac{\pi}{3}}\ln(1+\sqrt{3}\tan x).dx=\frac{\pi}{3}\ln 2}$ ។

# លំហាត់ទី២៤

គេឱ្យ f ជាអនុគមន៍ជាប់លើ [0,1] ។

ចូរបង្ហាញថា $\int_0^{\pi} x.f(\sin x).dx = \frac{\pi}{2}\int_0^{\pi} f(\sin x).dx$ ?

អនុវត្តន៍: ចូរគណនា $I = \int_0^{\pi} \frac{x\sin x.dx}{1+\cos^2 x}$ ។

# ដំណោះស្រាយ

បង្ហាញថា $\int_0^{\pi} x.f(\sin x).dx = \frac{\pi}{2}\int_0^{\pi} f(\sin x).dx$

តាង $x = \pi - t$ នាំឱ្យ $dx = -dt$

និង ចំពោះ $x \in [0, \pi]$ នាំឱ្យ $t \in [\pi, 0]$

គេបាន $\int_0^{\pi} x.f(\sin x).dx = -\int_{\pi}^{0} (\pi - t).f[\sin(\pi - t)].dt$

$$\int_0^{\pi} x.f(\sin x).dx = \int_0^{\pi} (\pi - t).f(\sin t).dt = \pi\int_0^{\pi} f(\sin t).dt - \int_0^{\pi} t.f(\sin t).dt$$

$$\int_0^{\pi} x.f(\sin x).dx = \pi\int_0^{\pi} f(\sin x).dx - \int_0^{\pi} x.f(\sin x).dx$$

នាំឱ្យគេទាញបាន $\int_0^{\pi} x.f(\sin x).dx = \frac{\pi}{2}\int_0^{\pi} f(\sin x).dx$ ។

អនុវត្តន៍៖ គណនា $I = \int_0^{\pi} \frac{x\sin x.dx}{1+\cos^2 x}$

គេមាន $I = \int_0^{\pi} \frac{x.\sin x.dx}{1+\cos^2 x} = \int_0^{\pi} x.\frac{\sin x.dx}{2-\sin^2 x} = \frac{\pi}{2}\int_0^{\pi} \frac{\sin x.dx}{2-\sin^2 x}$

តាង $z = \cos x$ នាំឱ្យ $dz = -\sin x.dx$

ហើយចំពោះ $x \in [0,\pi]$ នោះ $z \in [1,-1]$

គេបាន $I = \frac{\pi}{2}\int_1^{-1} \frac{-dz}{1+z^2} = \frac{\pi}{2}\left[\arctan z\right]_{-1}^{1} = \frac{\pi}{2}\left(\frac{\pi}{4}+\frac{\pi}{4}\right) = \frac{\pi^2}{4}$ ។

ដូចនេះ $\boxed{I = \int_0^{\pi} \frac{x\sin x.dx}{1+\cos^2 x} = \frac{\pi^2}{4}}$ ។

## លំហាត់ទី២៥

គេឱ្យ $f$ ជាអនុគមន៍គូលើ $[-a,a]$ ។

ក. ចូរបង្ហាញថា $\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_{0}^{a}f(x).dx\ ,\ q>0\ ,q\neq 1$ ។

ខ. អនុវត្តន៍ ៖ គណនា $I=\int_{-\pi}^{\pi}\frac{\sqrt{2+2\cos 2x}}{1+3^x}.dx$

## ដំណោះស្រាយ

ក.បង្ហាញថា $\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_{0}^{a}f(x).dx\ ,\ q>0\ ,q\neq 1$ ។

គេមាន $\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_{-a}^{0}\frac{f(x).dx}{1+q^x}+\int_{0}^{a}\frac{f(x).dx}{1+q^x}\ (1)$

តាង $x=-t$ នាំឱ្យ $dx=-dt$ និងចំពោះ $x\in[-a,0]$ នាំឱ្យ $t\in[a,0]$

គេបាន $\int_{-a}^{0}\frac{f(x).dx}{1+q^x}=-\int_{a}^{0}\frac{f(-t).dt}{1+q^{-t}}=\int_{0}^{a}\frac{q^t.f(-t)dt}{1+q^t}=\int_{0}^{a}\frac{q^x f(-x).dx}{1+q^x}$

ដោយ $f(x)$ ជាអនុគមន៍គូនោះ $f(-x)=f(x)\ ,\ \forall x\in[-a,a]$

គេទាញបាន $\int_{-a}^{0}\frac{f(x).dx}{1+q^x}=\int_{0}^{a}\frac{q^x.f(x)}{1+q^x}.dx\ (2)$

យក (2) ទៅជួសក្នុង (1) គេបាន៖

$$\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_0^a\frac{q^x.f(x).dx}{1+q^x}+\int_0^a\frac{f(x).dx}{1+q^x}=\int_0^a\frac{(q^x+1)f(x).dx}{1+q^x}=\int_0^a f(x).dx$$

ដូចនេះ $\int_{-a}^{a}\frac{f(x).dx}{1+q^x}=\int_0^a f(x).dx\ ,\ q>0\ ,q\neq 1$ ។

ខ. អនុវត្តន៍ ៖ គណនា $I=\int_{-\pi}^{\pi}\frac{\sqrt{2+2\cos 2x}}{1+3^x}.dx$

ដោយ $f(x)=\sqrt{2+2\cos 2x}$ ជាអនុគមន៍គូនោះគេបាន៖

$$I=\int_0^{\pi}\sqrt{2+2\cos 2x}.dx=2\int_0^{\pi}|\cos x|.dx$$

$$=2\int_0^{\frac{\pi}{2}}\cos x.dx-2\int_{\frac{\pi}{2}}^{\pi}\cos x.dx$$

$$=2\left[\sin x\right]_0^{\frac{\pi}{2}}-2\left[\sin x\right]_{\frac{\pi}{2}}^{\pi}=2(1-0)-2(0-1)=4$$

ដូចនេះ $\boxed{I=4}$ ។

# លំហាត់ទី២៦

គេមានអាំងតេក្រាល $I=\int_0^{\frac{\pi}{4}}\cos^2 x.dx$ និង $J=\int_0^{\frac{\pi}{4}}\sin^2 x.dx$

ក-ចូរគណនា $I+J$ និង $I-J$ ។

ខ-ទាញរកតម្លៃនៃ $I$ និង $J$ ។

# ដំណោះស្រាយ

ក-គណនា $I+J$ និង $I-J$

យើងបាន $I+J=\int_0^{\frac{\pi}{4}}\cos^2 x.dx+\int_0^{\frac{\pi}{4}}\sin^2 x.dx$

$$=\int_0^{\frac{\pi}{4}}(\cos^2 x+\sin^2 x).dx=\int_0^{\frac{\pi}{4}}dx=\frac{\pi}{4}$$

ដូចនេះ $\boxed{I+J=\frac{\pi}{4}}$ ។

យើងបាន $I-J=\int_0^{\frac{\pi}{4}}\cos^2 x.dx-\int_0^{\frac{\pi}{4}}\sin^2 x.dx$

$$=\int_0^{\frac{\pi}{4}}(\cos^2 x-\sin^2 x).dx=\int_0^{\frac{\pi}{4}}\cos 2x dx$$

$$=\left[\frac{1}{2}\sin 2x\right]_0^{\frac{\pi}{4}}=\frac{1}{2}\sin\frac{\pi}{2}-\frac{1}{2}\sin 0=\frac{1}{2}$$

ដូចនេះ $\boxed{I-J=\frac{1}{2}}$ ។

ខ-ទាញរកតម្លៃនៃ $I$ និង $J$

គេមាន $\begin{cases} I+J=\frac{\pi}{4} \\ I-J=\frac{1}{2} \end{cases}$

នាំឱ្យ $I=\frac{\pi}{8}+\frac{1}{4}$ និង $J=\frac{\pi}{8}-\frac{1}{4}$ ។

# លំហាត់ទី២៧

គេឱ្យអាំងតេក្រាល $I_n=\int_0^1 \frac{e^{nx}}{e^x+1}.dx\ ,\ n\in IN$ ។

ក-គណនា $I_0+I_1\ ,I_1$ រួចទាញរក $I_0$ ។

ខ-គណនា $I_n+I_{n+1}$ ជាអនុគមន៍នៃ $n$ ។

# ដំណោះស្រាយ

ក-គណនា $I_0+I_1\ ,I_1$ រួចទាញរក $I_0$

យើងមាន $I_0=\int_0^1 \frac{1}{e^x+1}.dx\ \ ,\ \ I_1=\int_0^1 \frac{e^x}{e^x+1}$

យើងបាន $I_0+I_1=\int_0^1 \frac{1}{e^x+1}.dx+\int_0^1 \frac{e^x}{e^x+1}.dx=\int_0^1 \frac{1+e^x}{e^x+1}.dx=\int_0^1 dx=1$

$$I_1=\int_0^1 \frac{e^x}{e^x+1}.dx=\int_0^1 \frac{(e^x+1)'}{(e^x+1)}.dx=\left[\ln(e^x+1)\right]_0^1=\ln(e+1)-\ln 2=\ln\frac{e+1}{2}$$

ដោយ $I_0+I_1=1$ នាំឱ្យ $I_0=1-I_1=1-\ln(\frac{e+1}{2})$ ។

ដូចនេះ $\boxed{I_0+I_1=1\ ,\ I_1=\ln\left(\frac{e+1}{2}\right)\ ,I_0=1-\ln\left(\frac{e+1}{2}\right)}$ ។

ខ-គណនា $I_n + I_{n+1}$ ជាអនុគមន៍នៃ $n$

យើងបាន $I_n + I_{n+1} = \int_0^1 \frac{e^{nx}}{e^x + 1}.dx + \int_0^1 \frac{e^{(n+1)x}}{e^x + 1}.dx$

$$= \int_0^1 \frac{e^{nx} + e^{(n+1)x}}{e^x + 1}.dx = \int_0^1 \frac{e^{nx}(1 + e^x)}{e^x + 1}.dx$$

$$= \int_0^1 e^{nx}.dx = \left[ \frac{1}{n} e^{nx} \right]_0^1 = \frac{e^n - 1}{n}$$

ដូចនេះ $\boxed{I_n + I_{n+1} = \frac{e^n - 1}{n}}$ ។

## លំហាត់ទី២៨

គេសន្មតថា $f$ ជាអនុគមន៍មួយកំនត់លើ $\mathbb{R}$ ហើយផ្ទៀងផ្ទាត់

ទំនាក់ទំនង: $f(x)+f(-x)=\sqrt{2-2\cos 2x}$ ។

ចូរគណនា $I=\int_{-\frac{\pi}{3}}^{\frac{\pi}{3}} f(x).dx$ ។

## ដំណោះស្រាយ

គណនា $I=\int_{-\frac{\pi}{3}}^{\frac{\pi}{3}} f(x).dx$

យើងមាន $I=\int_{-\frac{\pi}{3}}^{\frac{\pi}{3}} f(x).dx=\int_{-\frac{\pi}{3}}^{0} f(x).dx+\int_{0}^{\frac{\pi}{3}} f(x).dx$

តាង $x=-t$ នាំឱ្យ $dx=-dt$

ចំពោះ $x\in\left[-\frac{\pi}{3}\,,0\right]$ នាំឱ្យ $t\in\left[\frac{\pi}{3},0\right]$

គេបាន $\int_{-\frac{\pi}{3}}^{0} f(x).dx = \int_{\frac{\pi}{3}}^{0} f(-t).(-dt) = \int_{0}^{\frac{\pi}{3}} f(-t).dt = \int_{0}^{\frac{\pi}{3}} f(-x).dx$

គេទាញ $I = \int_{0}^{\frac{\pi}{3}} f(-x).dx + \int_{0}^{\frac{\pi}{3}} f(x).dx = \int_{0}^{\frac{\pi}{3}} \left[ f(-x) + f(x) \right].dx$

ដោយ $f\left(x\right) + f\left(-x\right) = \sqrt{2 - 2\cos 2x} = \sqrt{4\sin^2 x} = 2\,|\sin x|$

គេបាន $I = \int_{0}^{\frac{\pi}{3}} 2\,|\sin x|\,.dx = 2\int_{0}^{\frac{\pi}{3}} \sin x.dx = 2\left[ -\cos x \right]_{0}^{\frac{\pi}{3}} = 2\left( -\frac{1}{2} + 1 \right) = 1$

ដូចនេះ $\boxed{I = \int_{-\frac{\pi}{3}}^{\frac{\pi}{3}} f\left(x\right).dx = 1}$ ។

# លំហាត់ទី២៩

ក-គណនាអាំងតេក្រាលកំនត់ $I_n = \int_0^1 (1+x)^n .dx \quad ,n \in IN$ ។

ខ-ទាញបង្ហាញថា $C_n^0 + \frac{1}{2}C_n^1 + \frac{1}{3}C_n^2 + ..... + \frac{1}{n+1}C_n^n = \frac{2^{n+1}-1}{n+1}$

# ដំណោះស្រាយ

ក-គណនាអាំងតេក្រាលកំនត់

$$I_n = \int_0^1 (1+x)^n .dx \quad ,n \in IN$$

$$= \left[ \frac{1}{n+1}(1+x)^{n+1} \right]_0^1 = \frac{1}{n+1}.2^{n+1} - \frac{1}{n+1}$$

$$= \frac{2^{n+1}-1}{n+1}$$

ខ-ទាញបង្ហាញថា $C_n^0 + \frac{1}{2}C_n^1 + \frac{1}{3}C_n^2 + ..... + \frac{1}{n+1}C_n^n = \frac{2^{n+1}-1}{n+1}$

តាមរូបមន្តទ្វេធាញូតុនគេមាន៖

$$(1+x)^n = C_n^0 + C_n^1 x + C_n^2 x^2 + ..... + C_n^n x^n$$

ធ្វើអាំងតេក្រាលកំនត់ក្នុងចន្លោះ $[0,1]$ នៃសមភាពនេះគេបាន៖

$$\int_0^1 (1+x)^n .dx = \int_0^1 \left( C_n^0 + C_n^1 x + C_n^2 x^2 + ..... + C_n^n x^n \right).dx$$

$$\frac{2^{n+1}-1}{n+1} = \left[ C_n^0 x + \frac{1}{2} C_n^1 x^2 + \frac{1}{3} C_n^2 x^3 + ...... + \frac{1}{n+1} C_n^n x^{n+1} \right]_0^1$$

$$\frac{2^{n+1}-1}{n+1} = C_n^0 + \frac{1}{2} C_n^1 + \frac{1}{3} C_n^2 + ............ + \frac{1}{n+1} C_n^n$$

ដូចនេះ $\boxed{C_n^0 + \frac{1}{2} C_n^1 + \frac{1}{3} C_n^2 + ..... + \frac{1}{n+1} C_n^n = \frac{2^{n+1}-1}{n+1}}$ ។

# លំហាត់ទី៣០

គេមានស្វីត $(I_n)$ កំនត់ចំពោះគ្រប់ $n \geq 1$ ដោយ ៖

$$I_n = \frac{1}{n!}.\int_0^1 (1-x)^n.e^x.dx$$

ក-ចូរគណនាតួ $I_1$ ។

ខ-ចូរបញ្ជាក់ $I_{n+1}$ ជាអនុគមន៍នៃ $I_n$ រួចទាញថា $I_n = e - \sum_{p=0}^{n}\left(\frac{1}{P!}\right)$

គ-ចូររកលីមីត $\lim_{n\to+\infty} I_n$

រួចទាញថា $\lim_{n\to+\infty}\left(1+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+....+\frac{1}{n!}\right) = e = 2.71828$

# ដំណោះស្រាយ

ក-ចូរគណនាតួ $I_1$

គេមាន $I_1 = \frac{1}{1!}\int_0^1 (1-x)e^x.dx = \int_0^1 (1-x).e^x.dx$

តាង $\begin{cases} u = 1-x \\ dv = e^x dx \end{cases}$ នាំឱ្យ $\begin{cases} du = -dx \\ v = e^x \end{cases}$

គេបាន $I=\left[(1-x)e^{x}\right]_0^1-\int_0^1 e^{x}(-dx)=-1+\left[e^{x}\right]_0^1=e-2$

ដូចនេះ $\boxed{I=e-2}$ ។

ខ-បញ្ជាក់ $I_{n+1}$ ជាអនុគមន៍នៃ $I_n$

គេមាន $I_n=\frac{1}{n!}.\int_0^1(1-x)^n.e^{x}.dx$

នាំឱ្យ $I_{n+1}=\frac{1}{(n+1)!}.\int_0^1(1-x)^{n+1}.e^{x}dx$

តាង $\begin{cases}u=(1-x)^{n+1}\\ dv=e^{x}dx\end{cases}$ នាំឱ្យ $\begin{cases}du=-(n+1)(1-x)^n\\ v=e^{x}\end{cases}$

គេបាន $I_{n+1}=\frac{1}{(n+1)!}\left[(1-x)^{n+1}e^{x}\right]_0^1+\frac{n+1}{(n+1)!}\int_0^1(1-x)^n e^{x}.dx$

$$I_{n+1}=-\frac{1}{(n+1)!}+\frac{1}{n!}\int_0^1(1-x)^n e^{x}dx=I_n-\frac{1}{(n+1)!}$$

ដូចនេះ $I_{n+1}=I_n-\frac{1}{(n+1)!}$ ។

ទាញឱ្យបានថា $I_n = e - \sum_{p=0}^{n}\left(\frac{1}{p!}\right)$

គេមាន $I_{n+1} = I_n - \frac{1}{(n+1)!}$ ឬ $I_{n+1} - I_n = -\frac{1}{(n+1)!}$

គេបាន $\sum_{k=1}^{n-1}\left(I_{k+1} - I_k\right) = -\sum_{k=1}^{n-1}\frac{1}{(k+1)!}$

$$I_n - I_1 = -\frac{1}{2!} - \frac{1}{3!} - .... - \frac{1}{n!}$$

ដោយ $I_1 = e - 2 = e - \frac{1}{0!} - \frac{1}{1!}$

គេបាន $I_n = e - \frac{1}{0!} - \frac{1}{1!} - \frac{1}{2!} - .... - \frac{1}{n!}$

ដូចនេះ $I_n = e - \sum_{p=0}^{n}\left(\frac{1}{p!}\right)$ ។

គ-ចូររកលីមីត $\lim_{n\to+\infty} I_n$

ចំពោះ $x \in [0, 1]$ គេមាន $1 \le e^x \le e$ និង $(1-x)^n \ge 0$

គេបាន $(1-x)^n \le e^x(1-x)^n \le e(1-x)^n$

នាំឱ្យ $\frac{1}{n!}\int_0^1 (1-x)^n.dx \le \frac{1}{n!}\int_0^1 (1-x)^n e^x.dx \le \frac{e}{n!}\int_0^1 (1-x)^n.dx$

ដោយ $\int_0^1 (1-x)^n.dx = \left[ -\frac{1}{n+1}(1-x)^{n+1} \right]_0^1 = \frac{1}{n+1}$

គេទាញបាន $\frac{1}{n!(n+1)} \le I_n \le \frac{e}{n!(n+1)}$ ។

កាលណា $n \to +\infty$ នាំឱ្យ $\frac{1}{n!(n+1)} \to 0$

ដូចនេះ $\boxed{\lim_{n\to+\infty} I_n = 0}$ ។

ទាញថា $\lim_{n\to+\infty}\left(1+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+....+\frac{1}{n!}\right) = e = 2.71828$

គេមាន $I_n = e - \sum_{p=0}^{n}\left(\frac{1}{p!}\right)$ នាំឱ្យ $\sum_{p=0}^{n}\left(\frac{1}{p!}\right) = e - I_n$

គេបាន $\lim_{n\to+\infty}\sum_{p=0}^{n}\left(\frac{1}{p!}\right) = \lim_{n\to+\infty}\left(e - I_n\right) = e$ ព្រោះ $\lim_{n\to+\infty} I_n = 0$

ដូចនេះ $\boxed{\lim_{n\to+\infty}\left(1+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+....+\frac{1}{n!}\right) = e = 2.71828}$

## លំហាត់ទី៣១

គេឲ្យអនុគមន៍ $f(x)=\left(\dfrac{x}{1-x^2}\right)^n$ ដែល $n\in IN$ និង $x\neq\pm1$ ។

ក/ចូរស្រាយថា $f'(x)=\dfrac{nx^{n-1}(1+x^2)}{(1-x^2)^{n+1}}$ ។

ខ/គេពិនិត្យ $I_n=\displaystyle\int_0^{\sqrt{2}-1}\frac{f(x).dx}{1+x^2}$ និង $J_n=\displaystyle\int_0^{\sqrt{2}-1}f'(x).dx$

ចូរស្រាយថា $I_{n-1}+4I_{n+1}=\dfrac{J_n}{n}$ គ្រប់ $n\in IN$ ។

គ/បង្ហាញថា $(I_n)$ ជាស្វីតចុះ រួចចំពោះគ្រប់ $n\geq 2$ ចូរបង្ហាញថា

$\dfrac{1}{5(n+1)2^{n+1}}\leq I_n\leq\dfrac{1}{5(n-1)2^{n-1}}$ ។

ឃ/គណនាលីមីត $\lim\limits_{n\to+\infty}(n\,2^n I_n)$ ។

## ដំណោះស្រាយ

ក/ស្រាយថា $f'(x)=\dfrac{nx^{n-1}(1+x^2)}{(1-x^2)^{n+1}}$

តាមរូបមន្ត $(u^n)'=nu'u^{n-1}$

គេបាន $f'(x)=n(\frac{x}{1-x^2})'(\frac{x}{1-x^2})^{n-1}$

$$=n\frac{1-x^2+2x^2}{(1-x^2)^2}\cdot\frac{x^{n-1}}{(1-x^2)^{n-1}}=\frac{nx^{n-1}(1+x^2)}{(1-x^2)^{n+1}}$$

ដូចនេះ $f'(x)=\frac{nx^{n-1}(1+x^2)}{(1-x^2)^{n+1}}$ ។

ខ/ស្រាយថា $I_{n-1}+4I_{n+1}=\frac{J_n}{n}$

គេបាន $I_n=\int_0^{\sqrt{2}-1}\frac{x^n dx}{(1-x^2)^n(1+x^2)}$ និង $J_n=\int_0^{\sqrt{2}-1}\frac{nx^{n-1}(1+x^2)}{(1-x^2)^{n+1}}.dx$

$$I_{n-1}+4I_{n+1}=\int_0^{\sqrt{2}-1}[\frac{x^{n-1}}{(1-x^2)^{n-1}(1+x^2)}+\frac{4x^{n+1}}{(1-x^2)^{n+1}(1+x^2)}].dx$$

$$=\int_0^{\sqrt{2}-1}\frac{x^{n-1}(1-x^2)^2+4x^{n+1}}{(1-x^2)^{n+1}(1+x^2)}.dx=\int_0^{\sqrt{2}-1}\frac{x^{n-1}(1+x^2)^2}{(1-x^2)^{n+1}(1+x^2)}.dx$$

$$=\int_0^{\sqrt{2}-1}\frac{x^{n-1}(1+x^2)}{(1-x^2)^{n+1}}.dx=\frac{1}{n}\int_0^{\sqrt{2}-1}f'(x).dx=\frac{1}{n}.J_n$$

ដូចនេះ $I_{n-1}+4I_{n+1}=\frac{J_n}{n}$ ។

គ/បង្ហាញថា $(I_n)$ ជាស្វ៊ីតចុះ

គេមាន $I_n = \int_0^{\sqrt{2}-1} \frac{x^n dx}{(1-x^2)^n(1+x^2)}$

តាង $x = \tan\frac{\varphi}{2}$ នាំឲ្យ $d\varphi = \frac{2dx}{1+x^2}$ និង $\tan\varphi = \frac{2x}{1-x^2}$

ចំពោះ $x = 0$ គេបាន $\tan\varphi = 0$ នោះ $\varphi = 0$

ចំពោះ $x = \sqrt{2}-1$ គេបាន $\tan\varphi = \frac{2(\sqrt{2}-1)}{1-(\sqrt{2}-1)^2} = 1$ នោះ $\varphi = \frac{\pi}{4}$

គេបាន $I_n = \frac{1}{2^{n+1}} \int_0^{\frac{\pi}{4}} \tan^n \varphi . d\varphi$

ចំពោះ $\varphi \in [0, \frac{\pi}{4}]$ គេមាន $\tan^n \varphi \geq \tan^{n+1} \varphi$

គេបាន $\frac{1}{2^{n+1}} \tan^n \varphi \geq \frac{1}{2^{n+1}} \tan^{n+1} \varphi \geq \frac{1}{2^{n+2}} \tan^{n+1} \varphi$

នោះ $\frac{1}{2^{n+1}} \int_0^{\frac{\pi}{4}} \tan^n \varphi . d\varphi \geq \frac{1}{2^{n+2}} \int_0^{\frac{\pi}{4}} \tan^{n+1} \varphi . d\varphi$ ឬ $I_n \geq I_{n+1}$ គ្រប់ $n \in IN$

ដូចនេះ $(I_n)$ ជាស្វ៊ីតចុះ ។

បង្ហាញថា ៖ $\frac{1}{5(n+1)2^{n+1}} \le I_n \le \frac{1}{5(n-1)2^{n-1}}$

គេមាន $I_{n-1} + 4I_{n+1} = \frac{J_n}{n}$

ហើយ $J_n = \int_0^{\sqrt{2}-1} f'(x).dx = \left[f(x)\right]_0^{\sqrt{2}-1} = \left[(\frac{x}{1-x^2})^n\right]_0^{\sqrt{2}-1} = \frac{1}{2^n}$

គេបាន $I_{n-1} + 4I_{n+1} = \frac{1}{n.2^n}$ គ្រប់ $n \ge 2$ ។

ដោយ $(I_n)$ ជាស្វ៊ីតចុះ នោះគេមាន $I_{n+2} \le I_n$ ឬ $I_n + 4I_{n+2} \le 5I_n$

តែ $I_{n-1} + 4I_{n+1} = \frac{1}{n.2^n}$ គេទាញ $I_n + 4I_{n+2} = \frac{1}{(n+1)2^{n+1}}$

ហេតុនេះ $5I_n \ge \frac{1}{(n+1)2^{n+1}}$ ឬ $I_n \ge \frac{1}{5(n+1).2^{n+1}}$ (1)

ម្យ៉ាងទៀត $I_n \le I_{n-2}$ ឬ $5I_n \le I_{n-2} + 4I_n$ តែ $I_{n-2} + 4I_n = \frac{1}{(n-1)2^{n-1}}$

ហេតុនេះ $5I_n \le \frac{1}{(n-1)2^{n-1}}$ ឬ $I_n \le \frac{1}{5(n-1)2^{n-1}}$ (2)

តាម(1)និង(2)គេបាន $\frac{1}{5(n+1)2^{n+1}} \le I_n \le \frac{1}{5(n-1)2^{n-1}}$ ។

ឃ/គណនាលីមីត $\lim\limits_{n\to+\infty}(n\,2^n I_n)$ ៖

តាមសម្រាយខាងលើគេមាន $\frac{1}{5(n+1)2^{n+1}} \le I_n \le \frac{1}{5(n-1)2^{n-1}}$

គុណអង្គទាំងពីរនឹង $n.2^n$ គេបាន $\frac{n}{10(n+1)} \le n2^n I_n \le \frac{1}{10(n-1)}$

ហេតុនេះ

$$\lim_{n\to\infty}\frac{n}{10(n+1)} \le \lim_{n\to\infty}(n2^n I_n) \le \lim_{n\to\infty}\frac{1}{10(n-1)}$$

$$\frac{1}{10} \le \lim_{n\to\infty}(n2^n I_n) \le \frac{1}{10}$$

ដូចនេះ $\lim\limits_{n\to+\infty}(n\,2^n I_n) = \frac{1}{10}$ ។

# លំហាត់ទី៣២

គេឲ្យអាំងតេក្រាល $I_n = \int_1^e \frac{x^{-(2n+1)}}{1+x^2}.dx$ ; $n = 0,1,2,....,e = 2.71828$

ក/គណនា $I_0$

ខ/បង្ហាញថា $I_n + I_{n+1} = \frac{e^{2n+2}-1}{2(n+1)e^{2n+2}}$

គ/គ្រប់ $x \geq 1$ ស្រាយថា $\frac{1}{2}x^{-2(n+1)} \leq \frac{x^{-2n}}{1+x^2} \leq \frac{1}{2}x^{-2n}$

ឃ/គណនាលីមីត $\lim_{n\to+\infty} I_n$ និង $\lim_{n\to+\infty} nI_n$ ។

# ដំណោះស្រាយ

ក/គណនា $I_0$

គេបាន $I_0 = \int_1^e \frac{dx}{x(x^2+1)} = \int_1^e (\frac{1}{x} - \frac{x}{1+x^2}).dx$

$$= \left[ \ln x - \frac{1}{2}\ln(1+x^2) \right]_1^e = \ln \frac{e\sqrt{2}}{\sqrt{1+e^2}}$$

ដូចនេះ $I = \ln \frac{e\sqrt{2}}{1+e^2}$ ។

ខ/បង្ហាញថា $I_n + I_{n+1} = \frac{e^{2n+2} - 1}{2(n+1)e^{2n+2}}$

គេបាន $I_n + I_{n+1} = \int_1^e \frac{x^{-(2n+3)} + x^{-(2n+1)}}{1+x^2}.dx$

$$= \int_1^e x^{-2n-3}.dx = \left[ -\frac{1}{2n+2} x^{-2n-2} \right]_1^e = \frac{1 - e^{-2n-2}}{2(n+1)}$$

ដូចនេះ $I_n + I_{n+1} = \frac{e^{2n+2} - 1}{2(n+1)e^{2n+2}}$ ។

គ/ ស្រាយថា $\frac{1}{2} x^{-2(n+1)} \le \frac{x^{-2n}}{1+x^2} \le \frac{1}{2} x^{-2n}$

គ្រប់ $x \ge 1$ គេមាន $x^{2n+2} \ge x^{2n}$

គេបាន $\frac{1}{x^{2n+2}} \le \frac{1}{x^{2n}}$ ឬ $x^{-2(n+1)} \le x^{-2n}$

$$\frac{1}{2} x^{-2(n+1)} \le \frac{1}{2} x^{-2n}$$

$$\frac{1}{2} x^{-2n} + \frac{1}{2} x^{-2(n+1)} \le x^{-2n}$$

$$\frac{1}{2} x^{-2(n+1)} (1 + x^2) \le x^{-2n}$$

គេទាញបាន $x^{-2(n+1)} \le \frac{x^{-2n}}{1+x^2}$ (1)

ម្យ៉ាងទៀត $\forall x \geq 1 :\ x^{2n} \geq x^{2n-2}$ ឬ $x^{-2n} \leq x^{-2n+2}$

គេទាញ $x^{-2n} \leq \frac{1}{2}x^{-2n+2} + \frac{1}{2}x^{-2n} = \frac{1}{2}x^{-2n}(1+x^2)$

នាំឲ្យ $\frac{1}{2}x^{-2n} \geq \frac{x^{-2n}}{1+x^2}$ (2)

តាម (1) និង (2) គេបាន $\frac{1}{2}x^{-2(n+1)} \leq \frac{x^{-2n}}{1+x^2} \leq \frac{1}{2}x^{-2n}$ គ្រប់ $x \geq 1$ ។

ឃ/គណនាលីមីត $\lim_{n\to\infty} I_n$ ៖

គេមាន $\frac{1}{2}x^{-2(n+1)} \leq \frac{x^{-2n}}{1+x^2} \leq \frac{1}{2}x^{-2n}$ គ្រប់ $x \geq 1$

គេបាន $\frac{1}{2}x^{-2n-3} \leq \frac{x^{-(2n+1)}}{1+x^2} \leq \frac{1}{2}x^{-2n-1}$

$$\frac{1}{2}\int_1^e x^{-2n-3}.dx \leq \int_1^e \frac{x^{-(2n+1)}}{1+x^2}.dx \leq \frac{1}{2}\int_1^e x^{-2n-1}.dx$$

$$-\frac{1}{4(n+1)}\left[x^{-2n-2}\right]_1^e \leq I_n \leq -\frac{1}{4n}\left[x^{-2n}\right]_1^e$$

$$\frac{1-e^{-2n-2}}{4(n+1)} \leq I_n \leq \frac{1-e^{-2n}}{4n}$$

ដោយ $\lim_{n\to\infty}\frac{1-e^{-2n-2}}{4(n+1)} = \lim_{n\to\infty}\frac{1-e^{-2n}}{4n} = 0$ ។

ដូចនេះ $\lim_{n\to+\infty} I_n = 0$

ហើយម្យ៉ាងទៀត $\frac{n(1-e^{-2n-2})}{4(n+1)} \le nI_n \le \frac{1-e^{-2n}}{4}$

ដោយ $\lim_{n\to+\infty} \frac{n(1-e^{-2n-2})}{4(n+1)} = \lim_{n\to+\infty} \frac{1-e^{-2n}}{4} = \frac{1}{4}$

ដូចនេះ $\lim_{n\to+\infty} nI_n = \frac{1}{4}$ ។

# លំហាត់ទី៣៣

គេឲ្យអនុគមន៍ f និង g កំណត់ដោយ ៖

$$f(x) = \arcsin(\sin x - \cos x)$$

$$g(x) = \ln(\sin x + \cos x + \sqrt{\sin 2x})$$

ក/គណនាដេរីវេនៃ $h(x) = f(x) - g(x)$ ។

ខ/ទាញរកអាំងតេក្រាល $I = \int_0^{\frac{\pi}{4}} \sqrt{\tan x}.dx$ ។

# ដំណោះស្រាយ

ក/គណនាដេរីវេនៃ $h(x) = f(x) - g(x)$

គេបាន $h'(x) = f'(x) - g'(x)$

ដោយ $f'(x) = \frac{(\sin x - \cos x)'}{\sqrt{1-(\sin x - \cos x)^2}} = \frac{\cos x + \sin x}{\sqrt{\sin 2x}}$

ហើយ $g'(x) = \frac{(\sin x + \cos x + \sqrt{\sin 2x})'}{\sin x + \cos x + \sqrt{\sin 2x}}$

$$g'(x) = \frac{\cos x - \sin x + \frac{\cos 2x}{\sqrt{\sin 2x}}}{\sin x + \cos x + \sqrt{\sin 2x}}$$

$$\frac{(\cos x-\sin x)+\frac{(\cos x-\sin x)(\cos x+\sin x)}{\sqrt{\sin 2x}}}{\sin x+\cos x+\sqrt{\sin 2x}}$$

$$=\frac{\cos x-\sin x}{\sqrt{\sin 2x}}$$

គេបាន $h'(x)=\frac{\cos x+\sin x}{\sqrt{\sin 2x}}-\frac{\cos x-\sin x}{\sqrt{\sin 2x}}=\frac{2\sin x}{\sqrt{2\sin x\cos x}}$

ដូចនេះ $h'(x)=\sqrt{2}.\sqrt{\tan x}$ ។

ខ/ទាញរកអាំងតេក្រាល $I=\int_0^{\frac{\pi}{4}}\sqrt{\tan x}.dx$

គេបាន $I=\frac{1}{\sqrt{2}}\int_0^{\frac{\pi}{4}}\sqrt{2}.\sqrt{\tan x}.dx=\frac{1}{\sqrt{2}}\int_0^{\frac{\pi}{4}}h'(x).dx=\frac{1}{\sqrt{2}}[h(\frac{\pi}{4})-h(0)]$

ដោយ $h(\frac{\pi}{4})=f(\frac{\pi}{4})-g(\frac{\pi}{4})=\arcsin(0)-\ln(\sqrt{2}+1)=-\ln(\sqrt{2}+1)$

និង $h(0)=\arcsin(-1)-\ln(1)=-\frac{\pi}{2}$ ។

ដូចនេះ $I=\frac{\sqrt{2}}{2}[\frac{\pi}{2}-\ln(\sqrt{2}+1)]$

## លំហាត់ទី៣៤

គេឲ្យអាំងតេក្រាល $I_n = \int_0^{\frac{\pi}{4}} \tan^n x\sqrt{\tan x}.dx \ , n = 0,1,2,...$ ។

ក/ស្រាយថា $(I_n)$ ជាស្វីតចុះរួចគណនា $I_0$ ។

ខ/គណនា $I_n + I_{n+2}$ ជាអនុគមន៍នៃ $n$ ។

គ/ស្រាយថា $\frac{1}{2n+3} \le I_n \le \frac{1}{2n-1}$ ។រកលីមីត $\lim_{n\to\infty} I_n$ និង $\lim_{n\to\infty}(nI_n)$ ។

## ដំណោះស្រាយ

ក/ស្រាយថា $(I_n)$ ជាស្វីតចុះរួចគណនា $I_0$ ៖

គេមាន $\forall x \in [o, \frac{\pi}{4}] : \ \tan^{n+1} x \le \tan^n x$

ឬ $\tan^{n+1} x.\sqrt{\tan x} \le \tan^n x.\sqrt{\tan x}$

គេបាន $\int_0^{\frac{\pi}{4}} \tan^{n+1} x\sqrt{\tan x}.dx \le \int_0^{\frac{\pi}{4}} \tan^n x\sqrt{\tan x}.dx$ ឬ $I_{n+1} \le I_n$ ។

ដូចនេះ $(I_n)$ ជាស្វីតចុះរួចគណនា ។

បើ $n=0$ គេបាន $I_0=\int_0^{\frac{\pi}{4}}\sqrt{\tan x}.dx$

តាង $\sqrt{\tan x}=t$ នោះ $dt=\frac{1+\tan^2 x}{2\sqrt{\tan x}}.dx=\frac{1+t^4}{2t}.dx$

នាំឲ្យ $dx=\frac{2t}{1+t^4}.dt$ ហើយចំពោះ $x\in[0,\frac{\pi}{4}]$ នោះ $t\in[0,1]$

គេបាន $I_0=\int_0^1\frac{2t^2}{1+t^4}.dt=\int_0^1\frac{(1+t^2)-(1-t^2)}{1+t^4}.dt$

$$=\int_0^1\frac{1+t^2}{1+t^4}dt-\int_0^1\frac{1-t^2}{1+t^4}.dt$$

យក $A=\int_0^1\frac{1+t^2}{1+t^4}.dt=\int_0^1\frac{1+\frac{1}{t^2}}{t^2+\frac{1}{t^2}}.dt=\int_0^1\frac{d(t-\frac{1}{t})}{(t-\frac{1}{t})^2+2}$

$$=\frac{1}{\sqrt{2}}\arctan(\frac{t^2-1}{t\sqrt{2}})\Big|_0^1=\frac{\pi}{2\sqrt{2}}$$

យក $B=\int_0^1\frac{1-t^2}{1+t^4}.dt=\int_0^1\frac{\frac{1}{t^2}-1}{t^2+\frac{1}{t^2}}.dt=-\int_0^1\frac{d(t+\frac{1}{t})}{(t+\frac{1}{t})^2-2}$

$$B = -\frac{1}{2\sqrt{2}}\ln\frac{t^2 - t\sqrt{2}+1}{t^2+t\sqrt{2}+1}\Bigg|_0^1$$

$$= -\frac{1}{2\sqrt{2}}\ln(\frac{2-\sqrt{2}}{2+\sqrt{2}}) = \frac{1}{\sqrt{2}}\ln(\sqrt{2}+1)$$

ដូចនេះ $I_0 = \frac{\pi}{2\sqrt{2}} - \frac{1}{\sqrt{2}}\ln(\sqrt{2}+1)$ ។

ខ/គណនា $I_n + I_{n+2}$ ជាអនុគមន៍នៃ $n$ ៖

គេបាន $I_n + I_{n+2} = \int_0^{\frac{\pi}{4}} (\tan^n x + \tan^{n+2} x)\sqrt{\tan x}.dx$

$$= \int_0^{\frac{\pi}{4}} \tan^{n+\frac{1}{2}} x.(1+\tan^2 x).dx$$

តាង $t = \tan x \Rightarrow dt = (1+\tan^2 x).dx$

ចំពោះ $x \in [0, \frac{\pi}{4}]$ នោះ $t \in [0,1]$

គេបាន $I_n + I_{n+2} = \int_0^1 t^{n+\frac{1}{2}}.dt = \left[\frac{2}{2n+3}t^{n+\frac{3}{2}}\right]_0^1 = \frac{2}{2n+3}$

ដូចនេះ $I_n + I_{n+2} = \frac{2}{2n+3}$ ។

គ/ស្រាយថា $\frac{1}{2n+3} \le I_n \le \frac{1}{2n-1}$ ៖

គេមាន $I_n + I_{n+2} = \frac{2}{2n+3}$ (1)

គេបាន $I_{n-2} + I_n = \frac{2}{2n-1}$ (2) គ្រប់ $n \ge 2$ ។

ដោយ $(I_n)$ជាស្វ៊ីតចុះនោះ $I_n + I_{n+2} \le 2I_n \le I_{n-2} + I_n$ (3)

តាម (1),(2)&(3) គេបាន $\frac{2}{2n+3} \le 2I_n \le \frac{2}{2n-1}$

ដូចនេះ $\frac{1}{2n+3} \le I_n \le \frac{1}{2n-1}$ ។

ឃ/គណនាលីមីត $\lim_{n\to\infty} I_n$ និង $\lim_{n\to\infty}(nI_n)$

គេមាន $\frac{1}{2n+3} \le I_n \le \frac{1}{2n-1}$ នោះ $\frac{n}{2n+3} \le nI_n \le \frac{n}{2n-1}$

ដូចនេះ $\lim_{n\to\infty} I_n = 0$ និង $\lim_{n\to\infty}(nI_n) = \frac{1}{2}$ ។

# លំហាត់ទី៣៥

គេឲ្យអាំងតេក្រាល ៖

$$I(\alpha)=\int_0^{\alpha}\left(\frac{2x+1}{\sqrt{x^2+x}}+\frac{2x+2}{\sqrt{x^2+2x}}+...+\frac{2x+n}{\sqrt{x^2+nx}}-\frac{2nx}{\sqrt{x^2+1}}\right).dx$$

ដែល $\alpha>0$ ។

ក/គណនា $I(\alpha)$

ខ/គណនាលីមីត $\lim\limits_{\alpha\to+\infty} I(\alpha)$ ។

# ដំណោះស្រាយ

ក/គណនា $I(\alpha)$ ៖

គេអាចសរសេរ $I(\alpha)=\int_0^{\alpha}\sum_{k=1}^{n}\left(\frac{2x+k}{\sqrt{x^2+kx}}-\frac{2x}{\sqrt{x^2+1}}\right).dx$

$$=\sum_{k=1}^{n}\int_0^{\alpha}\left(\frac{2x+k}{\sqrt{x^2+kx}}-\frac{2x}{\sqrt{x^2+1}}\right).dx$$

$$=\sum_{k=1}^{n}\left[2\sqrt{x^2+kx}-2\sqrt{x^2+1}\right]_0^{\alpha}$$

ដូចនេះ $I(\alpha)=2\sum_{k=1}^{n}(\sqrt{\alpha^2+k\alpha}-\sqrt{\alpha^2+1}+1]$ ។

ខ/គណនាលីមីត $\lim\limits_{\alpha\to+\infty} I(\alpha)$ ៖

គេមាន $I(\alpha)=2\sum_{k=1}^{n}(\sqrt{\alpha^2+k\alpha}-\sqrt{\alpha^2+1}+1]$

$$=2\sum_{k=1}^{n}\left[\frac{k\alpha-1}{\sqrt{\alpha^2+k\alpha}+\sqrt{\alpha^2+1}}+1\right]$$

$$=2\sum_{k=1}^{n}\left[\frac{k-1/\alpha}{\sqrt{1+k/\alpha}+\sqrt{1+1/\alpha^2}}+1\right]$$

ដូចនេះ $\lim\limits_{\alpha\to+\infty} I(\alpha)=2\sum_{k=1}^{n}(\frac{k}{2}+1)=\frac{n(n+5)}{2}$ ។

## លំហាត់ទី៣៦

គេឲ្យអាំងតេក្រាល $I=\int_0^1 \frac{x^n}{\sqrt{1-x^2}}.dx$ ដែល $n=0,1,2,...$ ។

ក/គណនា $I_0$ និង $I_1$ រួចស្រាយថា $(I_n)$ ជាស្វ៊ីតចុះ ។

ខ/សរសេរទំនាក់ទំនងរវាងតួ $I_n$ និង $I_{n+2}$ រួចគណនាលីមីត $\lim_{n\to+\infty}\frac{I_{n+2}}{I_n}$ ។

គ/គណនាផលគុណ $P_n=I_n.I_{n+1}$ ជាអនុគមន៍នៃ $n$ ។

ឃ/គណនា $\lim_{n\to+\infty}\frac{I_{n+1}}{I_n}$ រួចទាញថា $\lim_{n\to+\infty}(\sqrt{n}.I_n)=\sqrt{\frac{\pi}{2}}$ ។

ង/រករូបមន្តសម្រាប់គណនា $I_n$ ។

ច/គណនាលីមីត $\lim_{n\to+\infty}\left(\frac{2\times4\times6\times....\times(2k)}{1\times3\times5\times.....\times(2k-1)}\right)^2\times\frac{1}{2k+1}$ ។

## ដំណោះស្រាយ

ក/គណនា $I_0$ និង $I_1$ រួចស្រាយថា $(I_n)$ ជាស្វ៊ីតចុះ ៖

ចំពោះ $n=0$ គេបាន ៖

$$I_0=\int_0^1\frac{dx}{\sqrt{1-x^2}}=\left[\operatorname{Arcsin}x\right]_0^1=\arcsin(1)-\arcsin(0)=\frac{\pi}{2}$$

ចំពោះ $n=1$ គេបាន ៖

$$I_1=\int_0^1\frac{x}{\sqrt{1-x^2}}.dx=-\frac{1}{2}\int_0^1\frac{(1-x^2)'}{\sqrt{1-x^2}}.dx\quad=-\frac{1}{2}\left[2\sqrt{1-x^2}\right]_0^1=1$$

ដូចនេះ $I_0=\frac{\pi}{2}$ និង $I_1=1$ ។

ខ/សរសេរទំនាក់ទំនងរវាងតួ $I_n$ និង $I_{n+2}$ ៖

គេមាន $I_n=\int_0^1\frac{x^n}{\sqrt{1-x^2}}.dx$ នាំឲ្យ $I_{n+2}=\int_0^1\frac{x^{n+2}}{\sqrt{1-x^2}}.dx$

តាង $\begin{cases}u=x^{n+1}\\ dv=\frac{x}{\sqrt{1-x^2}}.dx\end{cases}\Rightarrow\begin{cases}du=(n+1)x^n.dx\\ v=-\sqrt{1-x^2}\end{cases}$

$$I_{n+2}=\left[-x^{n+1}\sqrt{1-x^2}\right]_0^1+(n+1)\int_0^1 x^n\sqrt{1-x^2}.dx$$

$$I_{n+2}=(n+1)\int_0^1\frac{x^n(1-x^2)}{\sqrt{1-x^2}}.dx=(n+1)\int_0^1\frac{x^n}{\sqrt{1-x^2}}.dx-(n+1)\int_0^1\frac{x^{n+2}}{\sqrt{1-x^2}}.dx$$

$I_{n+2}=(n+1)I_n-(n+1)I_{n+2}$ នាំឲ្យ $I_{n+2}=\frac{n+1}{n+2}I_n$ ។

ដូចនេះ $I_{n+2}=\frac{n+1}{n+2}I_n$ ។

គណនាលីមីត $\lim\limits_{n\to+\infty}\frac{I_{n+2}}{I_n}$ ៖

គេមាន $I_{n+2}=\frac{n+1}{n+2}I_n$ គេទាញ $\frac{I_{n+2}}{I_n}=\frac{n+1}{n+2}$

គេបាន $\lim\limits_{n\to+\infty}\frac{I_{n+2}}{I_n}=\lim\limits_{n\to+\infty}\frac{n+1}{n+2}=1$ ។

គ/គណនាផលគុណ $P_n=I_n.I_{n+1}$ ជាអនុគមន៍នៃ $n$ ៖

គេមាន $P_n=I_n.I_{n+1}$ នោះ $P_{n+1}=I_{n+1}.I_{n+2}$ តែ $I_{n+2}=\frac{n+1}{n+2}I_n$

គេបាន $P_{n+1}=I_{n+1}\times\frac{n+1}{n+2}I_n=\frac{n+1}{n+2}P_n$ ឬ $\frac{P_{n+1}}{P_n}=\frac{n+1}{n+2}$

គេទាញ $\prod\limits_{k=0}^{n-1}\frac{P_{k+1}}{P_k}=\prod\limits_{k=0}^{n-1}\frac{k+1}{k+2}$ ឬ $\frac{P_n}{P_0}=\frac{1}{2}\times\frac{2}{3}\times\frac{3}{4}\times\ldots\times\frac{n}{n+1}=\frac{1}{n+1}$

ដោយ $P_0=I_0.I_1=\frac{\pi}{2}$

ដូចនេះ $P_n=I_nI_{n+1}=\frac{\pi}{2}.\frac{1}{n+1}$ ។

ឃ/គណនា $\lim\limits_{n\to+\infty}\frac{I_{n+1}}{I_n}$ រួចទាញថា $\lim\limits_{n\to+\infty}(\sqrt{n}.I_n)=\sqrt{\frac{\pi}{2}}$ ៖

គេមាន $(I_n)$ជាស្វីតចុះនោះ $I_{n+2}\le I_{n+1}\le I_n$

គេទាញ $\frac{I_{n+2}}{I_n} \le \frac{I_{n+1}}{I_n} \le 1$ ឬ $\frac{n+1}{n+2} \le \frac{I_{n+1}}{I_n} \le 1$ ដោយ $\lim_{n\to\infty}\frac{n+1}{n+2} = 1$

ដូចនេះ $\lim_{n\to+\infty}\frac{I_{n+1}}{I_n} = 1$ ។

ម្យ៉ាងទៀតគេមាន $P_n = I_n I_{n+1} = \frac{\pi}{2}.\frac{1}{n+1}$

គេទាញ $n I_n{}^2 = \frac{\pi}{2}.\frac{n}{n+1}.\frac{I_n}{I_{n+1}}$ ឬ $\sqrt{n}\, I_n = \sqrt{\frac{\pi}{2}} \times \sqrt{\frac{n}{n+1}} \times \sqrt{\frac{I_n}{I_{n+1}}}$

គេបាន $\lim_{n\to\infty}\sqrt{n}\, I_n = \sqrt{\frac{\pi}{2}}.\lim_{n\to\infty}\sqrt{\frac{n}{n+1}}.\lim_{n\to\infty}\sqrt{\frac{I_n}{I_{n+1}}} = \sqrt{\frac{\pi}{2}}$

ដូចនេះ $\lim_{n\to+\infty}(\sqrt{n}.I_n) = \sqrt{\frac{\pi}{2}}$ ។

ង/រករូបមន្តសម្រាប់គណនា $I_n$ ៖

គេមាន $\frac{I_{n+2}}{I_n} = \frac{n+1}{n+2}$ គ្រប់ $n = 0 , 1 , 2 ,3,...$

-ករណី $n = 2p$ (គូ)

គេបាន $\frac{I_{2p+2}}{I_{2p}} = \frac{2p+1}{2p+2}$ នាំឲ្យ $\prod_{p=0}^{k-1}\left(\frac{I_{2p+2}}{I_{2p}}\right) = \prod_{p=0}^{k-1}\left(\frac{2p+1}{2p+2}\right)$

ឬ $\frac{I_{2k}}{I_0}=\frac{1\times 3\times 5\times ....\times(2k-1)}{2\times 4\times 6\times ......\times(2k)}$ ដោយ $I_0=\frac{\pi}{2}$

ដូចនេះ $I_{2k}=\frac{1\times 3\times 5\times ....\times(2k-1)}{2\times 4\times 6\times ....\times(2k)}\times\frac{\pi}{2}$ ។

-ករណី $n=2p-1$ (សេស)

គេបាន $\frac{I_{2p+1}}{I_{2p-1}}=\frac{2p}{2p+1}$ នាំឲ្យ $\prod_{p=1}^{k}\left(\frac{I_{2p+1}}{I_{2p-1}}\right)=\prod_{p=1}^{k}\left(\frac{2p}{2p+1}\right)$

ឬ $\frac{I_{2k+1}}{I_1}=\frac{2\times 4\times 6\times ....\times(2k)}{3\times 5\times 7\times ......\times(2k+1)}$ ដោយ $I_1=1$

ដូចនេះ $I_{2k+1}=\frac{2\times 4\times 6\times ....\times(2k)}{3\times 5\times 7\times ......\times(2k+1)}$ ។

ច/គណនាលីមីត $\lim\limits_{n\to+\infty}\left(\frac{2\times 4\times 6\times ....\times(2k)}{1\times 3\times 5\times .....\times(2k-1)}\right)^2\times\frac{1}{2k+1}$

គេមាន $I_{2k+1}=\frac{2\times 4\times 6\times ....\times(2k)}{3\times 5\times 7\times ......\times(2k+1)}$ (1)

និង $I_{2k}=\frac{1\times 3\times 5\times ....\times(2k-1)}{2\times 4\times 6\times ....\times(2k)}\times\frac{\pi}{2}$ (2)

ចែក(1)និង(2)គេបាន $\frac{I_{2k+1}}{I_{2k}}=\left(\frac{2\times 4\times 6\times ....\times(2k)}{1\times 3\times 5\times .....\times(2k-1)}\right)^2\times\frac{1}{2k+1}\times\frac{2}{\pi}$

គេទាញ $\left(\frac{2\times 4\times 6\times ....\times(2k)}{1\times 3\times 5\times .....\times(2k-1)}\right)^2\times\frac{1}{2k+1}=\frac{\pi}{2}.\frac{I_{2k+1}}{I_{2k}}$

$$\lim_{k\to+\infty}\left(\frac{2\times 4\times 6\times ....\times(2k)}{1\times 3\times 5\times .....\times(2k-1)}\right)^2\times\frac{1}{2k+1}=\frac{\pi}{2}\lim_{k\to+\infty}\frac{I_{2k+1}}{I_{2k}}$$

គេមាន $(I_n)$ ជាស្វ៊ីតចុះនោះ $I_{2k+2}\le I_{2k+1}\le I_{2k}$ គ្រប់ $k=0,1,2,...$

គេបាន $\frac{I_{2k+2}}{I_{2k}}\le\frac{I_{2k+1}}{I_{2k}}\le 1$ ដោយ $\frac{I_{n+2}}{I_n}=\frac{n+1}{n+2}$ នោះ $\frac{I_{2k+2}}{I_{2k}}=\frac{2k+1}{2k+2}$

ហេតុនេះ $\frac{2k+1}{2k+2}\le\frac{I_{2k+1}}{I_{2k}}\le 1$ ដោយ $\lim_{k\to\infty}\frac{2k+1}{2k+2}=1$ នោះ $\lim_{k\to\infty}\frac{I_{2k+1}}{I_{2k}}=1$

ដូចនេះ $\lim_{k\to+\infty}\left(\frac{2\times 4\times 6\times ....\times(2k)}{1\times 3\times 5\times .....\times(2k-1)}\right)^2\times\frac{1}{2k+1}=\frac{\pi}{2}$ ។

## លំហាត់ទី៣៧

ចូរស្រាយបញ្ជាក់ថា ៖

$$\frac{\pi}{3\sqrt{3}} \le \int_0^1 \frac{dx}{x^3+x^2+1} \le \frac{\pi}{4}$$

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា ៖

$$\frac{\pi}{3\sqrt{3}} \le \int_0^1 \frac{dx}{x^3+x^2+1} \le \frac{\pi}{4}$$

គ្រប់ $x \in [0,1]$ គេមាន $0 \le x^3 \le x^2 \le x \le 1$

គេទាញ $x^2+1 \le x^3+x^2+1 \le x^2+x+1$

$$\frac{1}{x^2+x+1} \le \frac{1}{x^3+x^2+1} \le \frac{1}{x^2+1}$$

$$\int_0^1 \frac{dx}{x^2+x+1} \le \int_0^1 \frac{dx}{x^3+x^2+1} \le \int_0^1 \frac{dx}{x^2+1}$$

ដោយ $\displaystyle\int_0^1 \frac{dx}{x^2+1} = \left[\arctan x\right]_0^1 = \frac{\pi}{4}$

ហើយ $\int_0^1 \frac{dx}{x^2+x+1} = \int_0^1 \frac{d(x+\frac{1}{2})}{(x+\frac{1}{2})^2+(\frac{\sqrt{3}}{2})^2}$

$$= \frac{2}{\sqrt{3}}\left[\text{Arc}\tan\left(\frac{2x+1}{\sqrt{3}}\right)\right]_0^1$$

$$= \frac{2}{\sqrt{3}}\left(\frac{\pi}{3}-\frac{\pi}{6}\right) = \frac{\pi}{3\sqrt{3}}$$

ដូចនេះ $\frac{\pi}{3\sqrt{3}} \le \int_0^1 \frac{dx}{x^3+x^2+1} \le \frac{\pi}{4}$ ។

## លំហាត់ទី៣៨

ក/គ្រប់ចំនួនពិត $x \geq 0$ ចូរស្រាយថា $e^{-x^2} \leq \frac{1}{1+x^2}$

ខ/ទាញបង្ហាញថា $\int_0^{\sqrt{3}} e^{-x^2}.dx \leq \frac{\pi}{3}$ ។

## ដំណោះស្រាយ

ក/គ្រប់ចំនួនពិត $x \geq 0$ ស្រាយថា $e^{-x^2} \leq \frac{1}{1+x^2}$

តាងអនុគមន៍ $f$ កំណត់គ្រប់ $x \geq 0$ ដោយ $f(x) = e^{x^2} - x^2 - 1$

គេបាន $f'(x) = 2x(e^{x^2} - 1) \geq 0$ គ្រប់ $x \geq 0$ នាំឲ្យ $f$ ជាអនុគមន៍កើន

គេបាន $x \geq 0$ នាំឲ្យ $f(x) \geq f(0) = 0$

គេទាញ $e^{x^2} \geq 1 + x^2$ នាំឲ្យ $\frac{1}{e^{x^2}} = e^{-x^2} \leq \frac{1}{1+x^2}$

ដូចនេះគ្រប់ $x \geq 0$ គេមាន $e^{-x^2} \leq \frac{1}{1+x^2}$ ។

ខ/ទាញបង្ហាញថា $\int_{0}^{\sqrt{3}} e^{-x^2}.dx \le \frac{\pi}{3}$

តាមសម្រាយខាងលើគ្រប់ $x \ge 0$ គេមាន $e^{-x^2} \le \frac{1}{1+x^2}$

គេបាន $\int_{0}^{\sqrt{3}} e^{-x^2}.dx \le \int_{0}^{\sqrt{3}} \frac{dx}{1+x^2}$

យក $I = \int_{0}^{\sqrt{3}} \frac{dx}{1+x^2}$ តាង $x = \tan\varphi \Rightarrow dx = (1+\tan^2\varphi).d\varphi$

ចំពោះ $x = 0 \Rightarrow \varphi = 0$ និង $x = \sqrt{3} \Rightarrow \varphi = \frac{\pi}{3}$

គេបាន $I = \int_{0}^{\sqrt{3}} \frac{dx}{1+x^2} = \int_{0}^{\frac{\pi}{3}} \frac{(1+\tan^2\varphi).d\varphi}{1+\tan^2\varphi} = \int_{0}^{\frac{\pi}{3}} d\varphi = \frac{\pi}{3}$

ដូចនេះ $\int_{0}^{\sqrt{3}} e^{-x^2}.dx \le \frac{\pi}{3}$ ។

# លំហាត់ទី៣៩

គេឱ្យស្វ៊ីត $(u_n)$ នៃចំនួនពិតកំនត់លើ $IN^*$ ដោយ

$$u_n = \frac{1}{n(n+1)(n+2)}$$ ។

ក.កំនត់ចំនួនពិត $A, B, C$ ដើម្បីអោយ

$$\frac{1}{n(n+1)(n+2)} = \frac{A}{n} + \frac{B}{n+1} + \frac{C}{n+2}$$ ។

ខ.តាង $S_n = u_1 + u_2 + u_3 + .... + u_n$ ។គណនា $\lim\limits_{n\to+\infty} S_n$

គ.ចំពោះគ្រប់ $n \in IN^*$ គេតាង $V_n = u_n - \int_n^{n+1} g(x).dx$ ដែល $g$

ជាអនុគមន៍កំនត់ដោយ $g(x) = \dfrac{1}{x(x+1)(x+2)}$

និង $S'_n = V_1 + V_2 + V_3 + ... + V_n$ ។

បង្ហាញថា $S'_n = S_n - \int_1^{n+1} g(x).dx$ ហើយទាញរក $S'_n$ និង $\lim\limits_{n\to+\infty} S'_n$

# ដំណោះស្រាយ

ក. កំនត់ចំនួនពិត $A, B, C$ ដែល

$$\frac{1}{n(n+1)(n+2)} = \frac{A}{n} + \frac{B}{n+1} + \frac{C}{n+2}$$

យើងបាន $1 = A(n+1)(n+2) + B(n+2)n + C(n+1)n$

សមមូល $1 = (A+B+C)n^2 + (3A+2B+C)n + 2A$

គេទាញ $\begin{cases} 2A = 1 \\ A+B+C = 0 \\ 3A+2B+C = 0 \end{cases}$

នាំឱ្យ $A = \frac{1}{2}$ , $B = -1$ , $C = \frac{1}{2}$ ។

ខ.គណនា $\lim_{n\to+\infty} S_n$

មាន $S_n = u_1 + u_2 + u_3 + .... + u_n = \sum_{k=1}^{n}(u_k)$

$$= \sum_{k=1}^{n}\left(\frac{1}{2k}-\frac{1}{k+1}+\frac{1}{2(k+2)}\right)$$

$$= \sum_{k=1}^{n}\left(\frac{1}{2k}-\frac{1}{2(k+1)}\right)-\sum_{k=1}^{n}\left(\frac{1}{2(k+1)}-\frac{1}{2(k+2)}\right)$$

$$= \frac{1}{2}-\frac{1}{2(n+1)}-\frac{1}{4}+\frac{1}{2(n+2)}=\frac{1}{4}-\frac{1}{2(n+1)}+\frac{1}{2(n+2)}$$

ដូចនេះ $\lim_{n\to+\infty} S_n = \lim_{n\to+\infty}\left[\frac{1}{4}-\frac{1}{2(n+1)}+\frac{1}{2(n+2)}\right]=\frac{1}{4}$ ។

គ.បង្ហាញថា$S'_n = S_n - \int_1^{n+1} g(x).dx$ ទាញរក $S'_n$ និង $\lim_{n\to+\infty} S'_n$

ចំពោះគ្រប់ $n \in IN^*$ យើងមាន$V_n = u_n - \int_n^{n+1} g(x).dx$

ដែល g ជាអនុគមន៍កំនត់ដោយ $g(x)=\frac{1}{x(x+1)(x+2)}$

និង $S'_n = V_1 + V_2 + V_3 + ... + V_n$

យើងបាន $S'_n = \sum_{k=1}^{n}(V_n) = \sum_{k=1}^{n}\left[u_n - \int_n^{n+1} g(x).dx\right]$

$$= \sum_{k=1}^{n}(u_n) - \left[\int_1^2 g(x).dx + \int_2^3 g(x).dx + ... + \int_n^{n+1} g(x).dx\right]$$

ដូចនេះ $S'_n = S_n - \int_1^{n+1} g(x).dx$ ។

ម្យ៉ាងទៀត $g(x)=\frac{1}{x(x+1)(x+2)}$ មានលំនាំដូច $u_n=\frac{1}{n(n+1)(n+2)}$

គេបាន $g(x)=\frac{1}{2x}-\frac{1}{x+1}+\frac{1}{2(x+2)}$

ដោយ $S_n=\frac{1}{4}-\frac{1}{2(n+1)}+\frac{1}{2(n+2)}$ យើងបាន ៖

$$S'_n=\frac{1}{4}-\frac{1}{2(n+1)}+\frac{1}{2(n+2)}-\int_1^{n+1}\left[\frac{1}{2x}-\frac{1}{x+1}+\frac{1}{2(x+2)}\right].dx$$

$$=\frac{1}{4}-\frac{n+2-n-1}{2(n+1)(n+2)}-\left[\frac{1}{2}\ln|x|-\ln|x+1|+\frac{1}{2}\ln|x+2|\right]_1^{n+1}$$

$$=\frac{1}{4}-\frac{1}{2(n+1)(n+2)}-\frac{1}{2}\ln(n+1)+\ln(n+2)-\frac{1}{2}\ln(n+3)+\frac{1}{2}\ln 3-\ln 2$$

$$=\frac{1}{4}+\ln\frac{\sqrt{3}}{2}-\frac{1}{2(n+1)(n+2)}+\ln\left[\frac{n+2}{\sqrt{(n+1)(n+3)}}\right]$$

ដូចនេះ $S'_n=\frac{1}{4}+\ln\frac{\sqrt{3}}{2}-\frac{1}{2(n+1)(n+2)}+\ln\left[\frac{n+2}{\sqrt{(n+1)(n+3)}}\right]$ ។

និង $\lim_{n\to+\infty}S'_n=\frac{1}{4}+\ln\frac{\sqrt{3}}{2}$ ។

## លំហាត់ទី៤០

ស្រាយថាផ្ទៃក្រឡារបស់រង្វង់ដែលមានផ្ចិត **O**កាំរង្វាស់ **R** ស្មើនឹង

$S=\pi R^2$ ។

## ដំណោះស្រាយ

រង្វង់ផ្ចិត **O** កាំ **R** មានសមីការ $x^2+y^2=R^2 \Rightarrow \left[\begin{array}{l} y=\sqrt{R^2-x^2} \\ y=-\sqrt{R^2-x^2} \end{array}\right.$




ផ្ទៃក្រឡារង្វង់កំណត់ដោយ $S=2\int_{-R}^{R}\sqrt{R^2-x^2}\,.\,dx$

តាង $x = R\sin t \Rightarrow dx = R\cos t.dt$

ចំពោះ $x \in [-R, R] \Rightarrow t \in [-\frac{\pi}{2}, \frac{\pi}{2}]$

គេបាន $S = 2\int_{-\frac{\pi}{2}}^{\frac{\pi}{2}} \sqrt{R^2 - R^2\sin^2 t}.R\cos t.dt$

$$= 2\int_{-\frac{\pi}{2}}^{\frac{\pi}{2}} R^2\cos^2 t.dt = 2R^2\int_{-\frac{\pi}{2}}^{\frac{\pi}{2}} \frac{1+\cos 2t}{2}.dt$$

$$= R^2\int_{-\frac{\pi}{2}}^{\frac{\pi}{2}} (1+\cos 2t).dt = R^2\left[t + \frac{1}{2}\sin 2t\right]_{-\frac{\pi}{2}}^{\frac{\pi}{2}}$$

$$= R^2[(\frac{\pi}{2} + \frac{1}{2}\sin\pi) - (-\frac{\pi}{2} - \frac{1}{2}\sin\pi)] = \pi R^2$$

ដូចនេះរង្វង់ផ្ចិត $O$ កាំរង្វាស់ $R$ មានផ្ទៃក្រឡាស្មើនឹង $S = \pi R^2$ ។

# លំហាត់ទី៤១

ចូររកក្រឡាផ្ទៃរបស់អេលីបដែលមានសមីការ $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ ។

## ដំណោះស្រាយ




គេមាន $\frac{x^2}{a^2}+\frac{y^2}{b^2}=1$

សមមូល $y=\pm b\sqrt{1-\frac{x^2}{a^2}}$

ក្រឡាផ្ទៃរបស់អេលីបគឺ ៖

$$S=2\int_{-a}^{a} b\sqrt{1-\frac{x^2}{a^2}}\ .dx$$

តាង $x=a\sin t \Rightarrow dx=a\cos t.dt$

ចំពោះ $x\in[-a,a]$ នោះ $t\in[-\frac{\pi}{2},\frac{\pi}{2}]$

គេបាន $S=2b\int_{-\frac{\pi}{2}}^{\frac{\pi}{2}}\sqrt{1-\sin^2 t}.a\cos t=2ab\int_{-\frac{\pi}{2}}^{\frac{\pi}{2}}\cos^2 t.dt=\pi ab$

ដូចនេះ $S=\pi ab$ ។

## លំហាត់ទី៤១

ចូរស្រាយថាកោណបរិវត្តន៍ដែលមានកាំថាសបាត **r** និង កម្ពស់ **h**

មានមាឌ $V = \frac{1}{3}\pi r^2 h$ ។

## ដំណោះស្រាយ




មាឌរបស់កោណបានមកពីរង្វិល

ក្រឡាផ្ទៃខណ្ឌដោយបន្ទាត់

$(OA): y = \frac{r}{h}x$ ជុំវិញអក្ស័(ox)

ក្នុងចន្លោះ [0,h] ។

គេបាន $V = \pi\int_0^h y^2.dx$

$$= \pi\int_0^h \frac{r^2}{h^2}x^2.dx = \frac{\pi r^2}{h^2}\left[\frac{x^3}{3}\right]_0^h = \frac{\pi r^2}{h^2}\left(\frac{h^3}{3} - 0\right) = \frac{1}{3}\pi r^2 h$$

ដូចនេះ $V = \frac{1}{3}\pi r^2 h$ ។

## លំហាត់ទី៤២

ក្នុងតម្រុយអរតូនរមេ $(o,\vec{i},\vec{j})$ គេឲ្យខ្សែកោង $(c): y = x^2$ ។

$A$ និង $B$ ជាពីរចំណុចនៃ $(c)$ ដែល $AB = 2a$ ( $a > 0$ ) ។

កំណត់កូអរដោនេនៃ $A$ និង $B$ ដើម្បីឲ្យផ្ទៃក្រឡាខណ្ឌដោយបន្ទាត់$(AB)$

និងខ្សែកោង $(c)$ មានតម្លៃអតិបរមា រួចកំណត់តម្លៃអតិបរមានោះ ។

## ដំណោះស្រាយ

កំណត់កូអរដោនេនៃ $y$ និង $B$ ៖

តាង $x_A$ និង $x_B$ ជាអាប់ស៊ីសនៃ

ចំណុច $A$ និង $B$ ។




គេបាន $A(x_A, x_A^2)$ និង $B(x_B, x_B^2)$

សមីការបន្ទាត់ $(AB)$ គឺ ៖

$$\frac{y - y_A}{x - x_A} = \frac{y_B - y_A}{x_B - x_A}$$

$$\frac{y - x_A^2}{x - x_A} = \frac{x_B^2 - x_A^2}{x_B - x_A} \Rightarrow y = (x_A + x_B)x - x_A x_B$$

តាង S ជាផ្ទៃក្រឡាខណ្ឌដោយបន្ទាត់(AB)និងខ្សែកោង $x_A$ ។

គេបាន $S=\int_{x_A}^{x_B}\left[(x_A+x_B)x-x_Ax_B-x^2\right].dx$

$$=\left[\frac{1}{2}(x_A+x_B)x^2-x_Ax_Bx-\frac{1}{3}x^3\right]_{x_A}^{x_B}$$

$$=\frac{1}{6}(x_B-x_A)^3 \quad (1)$$

គេមាន $AB=2a$ នោះ $AB^2=4a^2$

គេបាន $(x_B-x_A)^2+(x_B^2-x_A^2)^2=4a^2$

$$(x_B-x_A)^2+(x_B-x_A)^2(x_B+x_A)^2=4a^2$$

គេទាញ $x_B-x_A=\dfrac{2a}{\sqrt{1+(x_A+x_B)^2}}$ (2)

យក(2)ជំនួសក្នុង(1)គេបាន ៖

$$S=\frac{1}{6}\times\frac{8a^3}{\left[\sqrt{1+(x_A+x_B)^2}\right]^3}=\frac{4a^3}{3}.\frac{1}{\left[\sqrt{1+(x_A+x_B)^2}\right]^3}$$

ដើម្បីឲ្យ Sមានតម្លៃអតិបរមាលុះត្រាតែ $1+(x_A+x_B)^2$ អប្បបរមា

គេទាញបាន $(x_A + x_B)^2 = 0$ នោះ $x_A = -x_B$

តាម(2)គេទាញបាន $2x_B = 2a$ នោះ $x_B = a$ ហើយ $x_A = -a$

ដូចនេះ $A(-a, a^2)$ និង $B(a, a^2)$ ។

ហើយផ្ទៃក្រឡាអតិបរមានោះគឺ $S_{max} = \dfrac{4a^3}{3}$ ។

# លំហាត់ទី៤៣

ក្នុងតម្រុយអរតូនរមេ $(o,\vec{i},\vec{j})$ គេឲ្យខ្សែកោង $(c): y = 4 - x^2$

និងបន្ទាត់ (D) មានមេគុណប្រាប់ទិស m វិលជុំវិញចំណុច $A(1,2)$ ។

កំណត់តម្លៃ m ដើម្បីឲ្យផ្ទៃក្រឡាខណ្ឌដោយខ្សែកោង (c) និងបន្ទាត់ (d)

មានតម្លៃអប្បបរមា រួចកំណត់តម្លៃអប្បបរមានោះ ។

# ដំណោះស្រាយ




សមការបន្ទាត់ $(d): y - 2 = m(x-1)$ ឬ $y = mx - m + 2$

សមីការអាប់ស៊ីសចំណុចប្រសព្វរវាងខ្សែកោង $(c)$ និងបន្ទាត់ $(d)$ ៖

$mx - m + 2 = 4 - x^2$ ឬ $x^2 + mx - m - 2 = 0 \ (E)$

ឌីសគ្រីមីណង់ $\Delta = m^2 + 4m + 8 = (m+2)^2 + 4 > 0 \ \forall m \in IR$

នោះសមីការ $(E)$ មានឬសពីរជានិច្ច ។ ហេតុនេះបន្ទាត់ $(d)$ កាត់ $(c)$ បាន

ពីរចំណុច $A$ និង $B$ ដែល $x_A + x_B = -m \ (1)$ ; $x_A x_B = -m - 2 \ (2)$

តាង $S$ ជាផ្ទៃក្រលាខណ្ឌដោយ $(d)$ និង $(c)$ ។

$$S = \int_{x_A}^{x_B} \left[ (4 - x^2) - (mx - m + 2) \right].dx$$

$$= \int_{x_A}^{x_B} (-x^2 - mx + m + 2).dx = \left[ -\frac{1}{3}x^3 - \frac{1}{2}mx^2 + (m+2)x \right]_{x_A}^{x_B}$$

$$= -\frac{1}{3}(x_B^3 - x_A^3) - \frac{1}{2}m(x_B^2 - x_A^2) + (m+2)(x_B - x_A)$$

$$= -\frac{1}{6}(x_B - x_A)[2(x_A^2 + x_A x_B + x_B^2) + 3m(x_A + x_B) - 6m - 12]$$

$$= -\frac{1}{6}(x_B - x_A)[2(x_A + x_B)^2 - 2x_A x_B + 3m(x_A + x_B) - 6m - 12] \ (3)$$

យក (1) និង (2) ជួសក្នុង (3) គេបាន ៖

$$S = -\frac{1}{6}(x_B - x_A)[2m^2 + 2m + 4 - 3m^2 - 6m - 12]$$

$$= -\frac{1}{6}\sqrt{(x_A + x_B)^2 - 4x_A x_B}\ (-m^2 - 4m - 8)$$

$$= \frac{1}{6}\sqrt{m^2 + 4m + 8}\ .\ (m^2 + 4m + 8) = \frac{1}{6}\left[\sqrt{(m+2)^2 + 4}\ \right]$$

ដើម្បីឲ្យ $S$មានតម្លៃអប្បបរមាលុះត្រាតែ $(m+2)^2 = 0$ នោះ $m = -2$

ហើយផ្ទៃក្រឡាអប្បបរមានោះគឺ $S_{min} = \frac{1}{3}$ ។

# លំហាត់ទី៤៤

គេឲ្យ $I(t)=\int_0^t \frac{3.dx}{4x^2+5x+1}$ ដែល $t>0$

ក/កំណត់ a និង b ដើម្បីឲ្យ $\frac{3}{4x^2+5x+1}=\frac{a}{x+1}+\frac{b}{4x+1}$

ខ/គណនា $I(t)$ ជាអនុគមន៍នៃ t រួចទាញរក $\lim_{t\to+\infty} I(t)$ ។

# ដំណោះស្រាយ

ក/កំណត់ a និង b ៖

$$\frac{3}{4x^2+5x+1}=\frac{a}{x+1}+\frac{b}{4x+1}$$
$$\frac{3}{4x^2+5x+1}=\frac{a(4x+1)+b(x+1)}{(x+1)(4x+1)}$$
$$\frac{3}{4x^2+5x+1}=\frac{(4a+b)x+(a+b)}{4x^2+5x+1}$$

គេទាញបាន $\begin{cases} a+b=3 \\ 4a+b=0 \end{cases}$ នាំឲ្យ $a=-1\ ,\ b=4$ ។

ដូចនេះ $a=-1\ ,\ b=4$ ។

ខ/គណនា $I(t)$ ជាអនុគមន៍នៃ $t$ ៖

ចំពោះ $a=-1$ , $b=4$ គេបាន $\dfrac{3}{4x^2+5x+1}=\dfrac{4}{4x+1}-\dfrac{1}{x+1}$

យើងបាន $I(t)=\int_0^t\left(\dfrac{4}{4x+1}-\dfrac{1}{x+1}\right).dx$

$$=\left[\ln|4x+1|-\ln|x+1|\right]_0^t$$

$$=\left[\ln\left|\frac{4x+1}{x+1}\right|\right]_0^t=\ln\left(\frac{4t+1}{t+1}\right)$$

ដូចនេះ $I=\ln\left(\dfrac{4t+1}{t+1}\right)$ ។

គណនាលីមីត $\lim\limits_{t\to+\infty}I(t)$ ៖

គេបាន $\lim\limits_{t\to+\infty}I(t)=\lim\limits_{t\to+\infty}\ln\left(\dfrac{4t+1}{t+1}\right)$ ដោយ $\lim\limits_{t\to+\infty}\dfrac{4t+1}{t+1}=4$

ដូចនេះ $\lim\limits_{t\to+\infty}I(t)=\lim\limits_{t\to+\infty}\ln\left(\dfrac{4t+1}{t+1}\right)=\ln 4$ ។

## លំហាត់ទី៤៥

គេតាង $\{a_n\}$ ជាស៊ីតកំនត់ដោយ $a_n = \int_0^{\frac{1}{n}} x\cos^2 x.dx \; ; (n = 1, 2, 3, ....)$

ចូររកតម្លៃ $\lim_{n\to+\infty} (n^2 a_n)$ ។

( ប្រឡងអាហារូបករណ៍ទៅប្រទេសចិនថ្នាក់ឧត្តមឆ្នាំ ២០០៧ )

## ដំណោះស្រាយ

រកតម្លៃ $\lim_{n\to+\infty} (n^2 a_n)$ ៖

គេមាន $a_n = \int_0^{\frac{1}{n}} x\cos^2 x.dx$ ដោយ $\cos^2 x = \frac{1+\cos 2x}{2}$

គេបាន $a_n = \frac{1}{2}\int_0^{\frac{1}{n}} x(1+\cos 2x).dx$

តាង $\begin{cases} u = x \\ dv = 1+\cos 2x \end{cases} \Rightarrow \begin{cases} du = dx \\ v = x + \frac{1}{2}\sin 2x \end{cases}$

$$a_n = \frac{1}{2}\left[x(x+\frac{1}{2}\sin 2x)\right]_0^{\frac{1}{n}} - \frac{1}{2}\int_0^{\frac{1}{n}}(x+\frac{1}{2}\sin 2x).dx$$

$$= \frac{1}{2}(\frac{1}{n^2}+\frac{1}{2n}\sin\frac{2}{n}) - \frac{1}{2}\left[\frac{x^2}{2}-\frac{1}{4}\cos 2x\right]_0^{\frac{1}{n}}$$

$$= \frac{1}{2}(\frac{1}{n^2}+\frac{1}{2n}\sin\frac{2}{n}) - \frac{1}{2}[(\frac{1}{2n^2}-\frac{1}{4}\cos\frac{2}{n})-(-\frac{1}{4})]$$

$$= \frac{1}{2n^2}+\frac{1}{4n}\sin\frac{2}{n}-\frac{1}{4n^2}+\frac{1}{8}\cos\frac{2}{n}-\frac{1}{8}$$

$$= \frac{1}{4n^2}+\frac{1}{4n}\sin\frac{2}{n}-\frac{1}{4}\sin^2\frac{1}{n}$$

គេបាន $\lim\limits_{n\to+\infty}(n^2a_n) = \lim\limits_{n\to+\infty}(\frac{1}{4}+\frac{n}{4}\sin\frac{2}{n}-\frac{n^2}{4}\sin^2\frac{1}{n})$

តាង $u=\frac{1}{n}$ ហើយកាលណា $n\to+\infty$ នោះ $u\to 0$

គេបាន $\lim\limits_{n\to+\infty}(n^2a_n) = \lim\limits_{u\to 0}(\frac{1}{4}+\frac{1}{4u}\sin 2u-\frac{1}{4u^2}\sin^2 u)$

$$= \lim_{u\to 0}(\frac{1}{4}+\frac{1}{2}.\frac{\sin 2u}{2u}-\frac{1}{4}.\frac{\sin^2 u}{u^2}) = \frac{1}{4}+\frac{1}{2}-\frac{1}{4}=\frac{1}{2}$$

ដូចនេះ $\lim\limits_{n\to+\infty}(n^2a_n)=\frac{1}{2}$ ។

# លំហាត់អនុវត្តន៍

១-ក/ចូរស្រាយបញ្ជាក់ថា $\sin^6 x+\cos^6 x=\frac{5}{8}+\frac{3}{8}\cos 4x$

ខ/ទាញរក $I=\int_0^{\frac{\pi}{8}}(\sin^6 x+\cos^6 x).dx$ ។

២-ក/ចូរស្រាយថា $\frac{1}{1+e^x}=1-\frac{1}{1+e^x}$

ខ/គណនា $I=\int_0^{\ln 2}\frac{dx}{1+e^x}$

៣-គេឲ្យអាំងតេក្រាល $I=\int_0^{\frac{\pi}{4}}\frac{\sin x}{\sin x+\cos x}.dx$ និង $J=\int_0^{\frac{\pi}{2}}\frac{\cos x}{\sin x+\cos x}.dx$

ក/គណនា $I+J$ និង $I-J$ ។

ខ/ទាញរក $I$ និង $J$

៤-គេឲ្យ $I=\int_0^{\frac{\pi}{2}}\sin^2 x.dx$ និង $J=\int_0^{\frac{\pi}{2}}\cos^2 x.dx$

ស្រាយថា $I=J$ រួចគណនា $I+J$ ហើយទាញរក $I$ និង $J$ ។

៥-គេឲ្យអាំងតេក្រាល $I=\int_0^1 \cos^n x.dx$ ដែល $n=0,1,2,...$ ។

ក/គណនា $I_0$ និង $I_1$ រួចស្រាយថា $(I_n)$ ជាស្វ៊ីតចុះ ។

ខ/សរសេរទំនាក់ទំនងរវាងតួ $I_n$ និង $I_{n+2}$ រួចគណនាលីមីត $\lim_{n\to+\infty}\frac{I_{n+2}}{I_n}$ ។

គ/គណនាផលគុណ $P_n=I_n.I_{n+1}$ ជាអនុគមន៍នៃ $n$ ។

ឃ/គណនា $\lim_{n\to+\infty}\frac{I_{n+1}}{I_n}$ រួចទាញថា $\lim_{n\to+\infty}(\sqrt{n}.I_n)=\sqrt{\frac{\pi}{2}}$ ។

ង/រករូបមន្តសម្រាប់គណនា $I_n$ ។

ច/គណនាលីមីត $\lim_{n\to+\infty}\left(\frac{2\times4\times6\times....\times(2k)}{1\times3\times5\times.....\times(2k-1)}\right)^2\times\frac{1}{2k+1}$ ។

៦-គណនា $I=\int_0^1\frac{dx}{x^2-x+1}$ និង $J=\int_0^1\frac{dx}{x^2+x+1}$

៧-ក/បង្ហាញថា $\frac{2x+1}{x^2(x+1)^2}=\frac{1}{x^2}-\frac{1}{(x+1)^2}$ គ្រប់ $x\neq0\ ,\ x\neq-1$ ។

ខ/គណនាអាំងតេក្រាល $I=\int_1^3\frac{2x+1}{x^2(x+1)^2}.dx$ ។

៨-ស្រាយបញ្ជាក់ថា $\int_0^{\alpha} x^3 f(x^2).dx = \frac{1}{2}\int_0^{\alpha^2} x f(x).dx \ , \alpha > 0$ ។

៩-ស្រាយបញ្ជាក់ថា $\int_0^{\frac{\pi}{2}} f(\sin x).dx = \int_0^{\frac{\pi}{2}} f(\cos x).dx$

១០-ស្រាយបញ្ជាក់ថាបើ **f** ជាអនុគមន៍សេសនោះគេបាន ៖

$$\int_a^b f(x).dx = \int_{-a}^{-b} f(x).dx$$ ។

១១-ក/ ឧបមាថា $t > 1$ ។ គណនា $I(t) = \int_1^t \frac{2x\ln x}{(1+x^2)^2}.dx$

ខ/គណនាលីមីត $\lim_{t\to+\infty} I(t)$ ។

១២-គណនាអាំងតេក្រាល $I = \int_0^1 \frac{dx}{x^4+1}$ ។

១៣-គេឲ្យអាំងតេក្រាល $I_n = \int_0^1 \frac{(2t)^n + (1-t^2)^n}{(1+t^2)^{n+1}}.dt$

ក/សរសេរទំនាក់ទំនងរវាង $I_n$ និង $I_{n+2}$ ។

ខ/ រករូបមន្តគណនា $I_n$ ។

១៤-គេឲ្យអាំងតេក្រាល ៖

$$I_n = \int_{\frac{\pi}{6}}^{\frac{\pi}{3}} \frac{\sqrt[n]{\sin x}}{\sqrt[n]{\sin x} + \sqrt[n]{\cos x}}.dx \quad \text{និង} \quad J_n = \int_{\frac{\pi}{6}}^{\frac{\pi}{3}} \frac{\sqrt[n]{\cos x}}{\sqrt[n]{\sin x} + \sqrt[n]{\cos x}}.dx$$

ក/ស្រាយថា $I_n = J_n$ ។

ខ/គណនា $I_n + J_n$ រួចទាញរក $I_n$ និង $J_n$ ។

១៥-ក/ស្រាយថា $\int_0^a f(x).dx = \int_0^a f(a-x).dx$

ខ/អនុវត្តន៍ ៖ គណនា $I = \int_0^{\frac{\pi}{4}} \ln(1+\tan x).dx$

១៦/គេឲ្យអាំងតេក្រាល $I_{2n+1} = \int_0^{\frac{\pi}{2}} \frac{\sin(2n+1)x}{\sin x}.dx$

គណនា $I_{2n+1} - I_{2n-1}$ រួចទាញរក $I_{2n+1}$ ។

១៧/គណនាអាំងតេក្រាល $I_n = \int_0^{+\infty} x^n e^{-x}.dx$ ។

(ប្រឡងនៅសហរដ្ឋអាមេរិចឆ្នាំ 1998 )

១៨-គេឲ្យ $I_n = \int_1^e (\ln x)^n .dx$

ក/ស្រាយថា $I_n = e - nI_{n-1}$ ។

ខ/គណនា $I_4$ ។

១៩-គេឲ្យ $I_n = \int_0^{\frac{\pi}{2}} \sin^n x.dx$

ក/រកទំនាក់ទំនងរបស់ $I_n$ ។

ខ/ទាញរក $I_4$ និង $I_5$

២០-គេឲ្យអនុគមន៍ $f(x) = \frac{\ln x}{x^2}$ , $x \geq 1$

ក/គណនា $\int f(x).dx$ ។

ខ/គេឲ្យ $a > 1$ ។ គណនា $I(a) = \int_1^a f(x).dx$ ។

គ/រក $\lim_{a \to +\infty} I(a)$ ។

២២-គណនាអាំងតេក្រាល $I = \int_0^{\frac{\pi}{3}} \frac{x\sin x}{\cos^2 x}.dx$ ។

២៣-គេអោយអាំងតេក្រាល ៖ $I_n = \int_0^{\frac{\pi}{2}} \sin^3 x \cos^{n-1} x \quad , n \in IN^*$

ក/គណនា $I_n$ ជាអនុគមន៍នៃ $n$ ។

ខ/គេតាង $S_n = I_1 + I_2 + I_3 + ... + I_n = \sum_{k=1}^{n} (I_k)$ ។

ចូរបង្ហាញថា $S_n = \frac{3}{2} - \frac{2n+3}{(n+1)(n+2)} \quad , n \in IN$ ។

គ/គណនាលីមីត $\lim_{n \to +\infty} S_n$ ។

២៤-គេអោយអាំងតេក្រាល $I_n = \int_0^{\frac{\pi}{2}} \sin^2 x \cos^n x . dx \quad , n \in IN$

ក/ស្រាយបញ្ជាក់ថា $(I_n)_{, n \in IN}$ ជាស្វ៊ីតចុះ រួចគណនា $I_0$ និង $I_1$

ខ/ផ្ទៀងផ្ទាត់ថាចំពោះគ្រប់ $n \geq 2$ គេមាន $I_n = \frac{n-1}{n+2} . I_{n-2}$ ។

គ/គេតាង $P_n = I_n . I_{n-1}$ ដែល $n \geq 1$ ។

គណនា $P_n$ ជាអនុគមន៍នៃ $n$ រួចគណនាលីមីត $\lim_{n \to +\infty} (n^2 . P_n)$ ។

ឃ/គេតាង $S_n = P_1 + P_2 + P_3 + ....... + P_n = \sum_{k=1}^{n} (P_k)$ ។

បង្ហាញថា $S_n = \frac{\pi}{8} \cdot \frac{n(n+3)}{(n+1)(n+2)}$ រួចទាញរកលីមីត $\lim_{n\to+\infty} S_n$ ។

ង/គណនា $\Pi_n = S_1 \times S_2 \times S_3 \times .... \times S_n$ ជាអនុគមន៍នៃ $n$ ។

ច/គណនា $I_{2n}$ និង $I_{2n+1}$ ជាអនុគមន៍នៃ $n$ ។

២៥-គេអោយអាំងតេក្រាល $I_n = \frac{1}{2n-1} \cdot \int_0^1 (x^2)^n .dx \ , n \in IN$ ។

ក/គណនា $I_n$ ជាអនុគមន៍នៃ $n$ ។

ខ/គណនា $S_n = I_1 + I_2 + I_3 + .... + I_n$ រួចទាញរកលីមីត $\lim_{n\to+\infty} S_n$

២៦-គេអោយអាំងតេក្រាល៖

$$I_n = \int_{na}^{(n+1)a} \frac{dx}{\cos^2 x} \text{ និង } J_n = \int_{a}^{(n+1)a} \frac{dx}{\cos^2 x} \ , n \in IN, a > 0 \text{ ។}$$

ក/បង្ហាញថា $I_1 + I_2 + I_3 + .... + I_n = J_n$ ។

ខ/គណនា $I_n$ និង $J_n$ ជាអនុគមន៍នៃ $n$ ។

គ/ប្រើលទ្ធផលខាងលើចូរបង្រួមផលបូក៖

$$S_n = \frac{1}{\cos a \cos 2a} + \frac{1}{\cos 2a \cos 3a} + .... + \frac{1}{\cos(na)\cos(n+1)a} \text{ ។}$$

២៧- គេអោយអាំងតេក្រាល៖

$$I_n = \int_0^{\frac{\pi}{2}} e^{-nx}\cos^2 x.dx \quad \text{និង} \quad J_n = \int_0^{\frac{\pi}{2}} e^{-nx}\sin^2 x.dx \ , n \in IN$$ ។

ក/គណនា $I_n + J_n$ នឹង $I_n - J_n$ ជាអនុគមន៍នៃ $n$ ។

ខ/ទាញអោយបាននូវតំលៃ $I_n$ នឹង $J_n$

២៨-គេអោយស្វ៊ីត $I_n = \int_{e^{-(n+1)\pi}}^{e^{-n\pi}} \cos(\ln x).dx \ , n \in IN$

ក/ស្រាយបញ្ជាក់ $(I_n)_{, n\in IN}$ ជាស្វ៊ីតធរណីមាត្រ ។

ខ/សរសេរកន្សោម $I_n$ ជាអនុគមន៍នៃ $n$ ។

គ/គណនាផលបូក $S_n = I_0 + I_1 + I_2 + ... + I_n$ រួចទាញរក $\lim_{n\to+\infty} S_n$ ។

២៩-គេអោយ $f$ ជាអនុគមន៍ មានខួប $p$ និងកំនត់លើ $[np,(n+1)p]$

ចំពោះគ្រប់ $n \in IN$ និង $a > 0, a \neq 1$ គេតាង $I_n = \int_{np}^{(n+1)p} a^x.f(x).dx$

ក/ស្រាយថា $(I_n), n \in IN$ ជាស្វ៊ីតធរណីមាត្រ។

ខ/សរសេរ $I_n$ ជាអនុគមន៍នៃ $n$ និង $I_0$ ។

គ/អនុវត្តន៍ ចូរគណនា $I_n = \int_{n\pi}^{(n+1)\pi} e^x.\cos 2x.dx$ ។

៣០-គេអោយអាំងតេក្រាល $I_n = \int_1^e \frac{x^{-(2n+1)}}{1+x^2}.dx \quad ,n \in IN, e = 2,71828...$

ក/ចូរគណនាតួ $I_0$ ។

ខ/ចូរបង្ហាញថាៈ $I_{n+1} + I_n = \frac{e^{2n+2} - 1}{2(n+1).e^{2n+2}}$ ។

គ/ចូរស្រាយបញ្ជាក់វិសមភាព៖

$$\frac{1}{2}x^{-2(n+1)} \le \frac{x^{-2n}}{1+x^2} \le \frac{1}{2}x^{-2n} \quad ,\forall x \ge 1$$ ។

ឃ/គណនាលីមីត $\lim_{n\to+\infty} I_n$ និង $\lim_{n\to+\infty}(nI_n)$ ។

៣១-គណនាអាំងតេក្រាល៖

$$I_n = \int_0^{\frac{\pi}{2}} \frac{dx}{1+\tan^n x} \quad \text{និង} \quad J_n = \int_0^{\frac{\pi}{2}} \frac{dx}{1+\cot^n x}$$

៣២-គេអោយស៊ីត $I_n = \int_0^1 \frac{t^n.dx}{1+t^2}$ $(n \in IN)$

ក/ស្រាយថា $(I_n)$ជាស៊ីតចុះ រួចគណនាតួ $I_0$ និង $I_1$ ។

ខ/សរសេរទំនាក់ទំនងរវាង $I_n$ និង $I_{n+2}$ ។

គ/ស្រាយបញ្ជាក់ថា $\frac{1}{2(n+1)} \le I_n \le \frac{1}{2(n-1)}$ $,\forall n \ge 2$ ។

ឃ/គណនាលីមីត $\lim_{n\to+\infty} I_n$ និង $\lim_{n\to+\infty} nI_n$ ។

៣៣-គេអោយអាំងតេក្រាលៈ

$$I_n = \int_{e^n}^{e^{n+1}} \frac{\ln x}{x^2}.dx \quad \forall n \in IN, e = 2,71828....$$

ក/ចូរបង្ហាយថា $I_n = \left(\frac{n}{e^n} - \frac{n+1}{e^{n+1}}\right) + \left(1 - \frac{1}{e}\right)\left(\frac{1}{e}\right)^n$

ខ/គណនា $\lim_{n\to+\infty} I_n$ ។

គ/គណនាផលបូក ៖ $S_n = \sum_{k=0}^{n}(I_k) = I_0 + I_1 + I_2 + .... + I_n$ ។

ទាញបញ្ជាក់លីមីត $\lim_{n\to+\infty} S_n$ ។

៣៤- គេអោយអាំងតេក្រាល ៖

$$I_n = \lim_{\lambda\to+\infty}\left[\int_1^{\lambda}\frac{1}{(1+x)^2}.\sqrt[n]{\frac{x-1}{x+1}}.dx\right]$$ ។

ក/ចូរបង្ហាញថា $I_n = \frac{1}{2}.\frac{n}{n+1}$ រួចទាញរក $\lim_{n\to+\infty} I_n$ ។

ខ/គណនា $P_n = \prod_{k=1}^{n}(I_k) = I_1.I_2.I_3....I_n$ ជាអនុគមន៍នៃ $n$ ។

៣៥-គេអោយស៊ីត ៖

$$I_n = \int_0^e x^n.dx \quad ,n\in IN, e = 2.71828...$$ ។

ក/គណនា $I_n$ ជាអនុគមន៍នៃ $n$ ។

ខ/គណនា $S_n = \frac{1}{I_0}+\frac{1}{I_1}+\frac{1}{I_2}+......+\frac{1}{I_n}$ ។

គ/ទាញបញ្ជាក់លីមីត $\lim_{n\to+\infty} S_n$ ។

៣៦-គេអោយស្វ៊ីតចំនួនពិត $(I_n), n \in IN$ ដោយ៖

$$I_n = \int_0^{\frac{\pi}{2}} \cos^n x \cos nx.dx$$

ក/គណនាតួ $I_0$ និង $I_1$ ។

ខ/ស្រាយថា $I_n$ ជាស្វ៊ីតធរណីមាត្រ រួចរក $I_n$ ជាអនុគមន៍នៃ $n$ ។

គ/គណនា $S_n = I_0 + I_1 + I_3 + ... + I_n$ រួចគណនា $\lim_{n \to +\infty} S_n$ ។

៣៧-គេអោយអនុគមន៍ៈ

$$y = f_n(x) = \int_{nx}^{(n+1)x} e^{-t^2}.dx \qquad \left( n \in IN \quad e = 2.71828... \right)$$

ក/គណនាដេរីវេ $y' = f'_n(x)$

ខ/ចំពោះគ្រប់ $n \in IN$ គេសន្មត $\Omega_n = f'_n(1)$ ។

ចូរគណនា $S_n = \Omega_1 + \Omega_2 + \Omega_3 + ... + \Omega_n$ រួចទាញរក $\lim_{n \to +\infty} S_n$ ។

៣៨-គេអោយអនុគមន៍ $f$ កំណត់លើ $[0,\pi]$ ។

ក/ចូរបង្ហាញថា: $\int_0^{\pi} xf(\sin x).dx = \pi\int_0^{\frac{\pi}{2}} f(\sin x).dx$ ។

ខ/អនុវត្តន៏គ:ណនា $I = \int_0^{\pi} \frac{x\sin x}{\sqrt{1+\sin^2 x}}.dx$ ។

៣៩-គេអោយស្វ៊ីត $I_n = \int_0^1 \frac{x^n}{\sqrt{x^2-x+1}}.dx$

ក/គណនាតួ $I_0$ និង $I_1$ ។

ខ/រកទំនាក់ទំនងរវាង $I_n$ ,$I_{n+1}$ និង $I_{n+2}$ ។

គ/អនុវត្តន៍: ចូរគណនា $k = \int_0^1 \frac{x^4}{\sqrt{x^2-x+1}}.dx$ ។

៤០-គេមានស្វ៊ីត $I_n = \int_0^1 x^n\sqrt{x^2-x+1}.dx$

ក/សរសេររូបមន្តកំណើនរបស់ $I_n$

ខ/គណនាតួ $I_0$ , $I_1$ និង $I_2$ ។

# រូបមន្តអាំងតេក្រាលសំខាន់ៗ

1/ $\int k.dx = kx + c$

2/ $\int x^n.dx = \frac{1}{n+1}.x^{n+1} + c$

3/ $\int \frac{dx}{x} = \ln|x| + c$

4 $\int \frac{dx}{x^2} = -\frac{1}{x} + c$

5/ $\int \frac{dx}{\sqrt{x}} = 2\sqrt{x} + c$

6/ $\int \sin x.dx = -\cos x + c$

7/ $\int \cos x.dx = \sin x + c$

8/ $\int \frac{dx}{\sin^2 x} = -\cot x + c$

9/ $\int \frac{dx}{\cos^2 x} = \tan x + c$

10/ $\int e^x.dx = e^x + c$

11/ $\int \frac{dx}{ax+b} = \frac{1}{a}.\ln|ax+b| + c$

12/ $\int \frac{dx}{\sqrt{ax+b}} = \frac{2}{a}.\sqrt{ax+b} + c$

13/ $\int \frac{dx}{x^2-a^2} = \frac{1}{2a}.\ln\left|\frac{x-a}{x+a}\right| + c$

14/ $\int \frac{dx}{x^2+a^2} = \frac{1}{a}.\text{arctn}(\frac{x}{a}) + c$

15/ $\int \frac{dx}{\sqrt{a^2-x^2}} = \arcsin\left(\frac{x}{a}\right) + c$

16/ $\int \frac{dx}{\sqrt{a^2+x^2}} = \ln\left|x+\sqrt{x^2+a^2}\right| + c$

17/ $\int \frac{dx}{\sqrt{x^2-a^2}} = \ln\left|x+\sqrt{x^2-a^2}\right| + c$

18/ $\int \frac{dx}{a^2-x^2} = \frac{1}{2a}.\ln\left|\frac{a+x}{a-x}\right| + c$

19/ $\int \cot x.dx = \ln|\sin x| + c$

20/ $\int \tan x.dx = -\ln|\cos x| + c$